Food and Agriculture Organization of the United Nations

This programme is co-funded by the European Union




# របាយការណ៍ ស្ថិតិផលនេសាទទឹកសាប ប្រចាំឆ្នាំ២០២៣

## របាយការណ៍ស្ថិតិ ស្តីពីការវាយតម្លៃផលនេសាទទឹកសាបក្នុងប្រទេសកម្ពុជា

**ខែមេសា ឆ្នាំ២០២៤**

*ការបោះពុម្ពផ្សាយនេះទទួលបានការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។ ខ្លឹមសារនៃការបោះផ្សាយនេះជាការទទួលខុសត្រូវរបស់រដ្ឋបាលជលផល និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។*

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្ថិតិប្រចាំឆ្នាំនេះ ត្រូវបានរៀបចំឡើងដោយមានជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ក្រោមជំនួយបច្ចេកទេសពីកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ន នៃអង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO CAPFISH) ជាមួយនឹងការសហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។ សូមថ្លែងអំណរគុណជាពិសេសចំពោះ លោកបណ្ឌិត **ហេង គង់** ប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប លោក **ចាយ គង់គ្រុយ** អនុប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបដែលបានផ្តល់ការណែនាំទូទៅ និងមតិយោបល់លើសេចក្តីព្រាងចុងក្រោយ និងលោក **សូត្រ សុបុត្រ** ដែលបានកែសម្រួលទិន្នន័យ និងរៀបចំតារាងស្ថិតិសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំបាយការណ៍ប្រចាំឆ្នាំនេះ។



**ឯកសារនេះរៀបចំដោយ:**
**បណ្ឌិត ហេង គង់ លោក សូត្រ សុបុត្រ និង លោក ចាយ គង់គ្រុយ**

ដោយមានជំនួយបច្ចេកទេសពីកម្មវិធី FAO CAPFISH



**គុណកថាបង្អែក:**
រដ្ឋបាលជលផល (២០២៤). របាយករណ៍ស្ថិតិស្តីពីការវាយតម្លៃផលនេសាទទឹកសាបក្នុងប្រទេសកម្ពុជា វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល ប្រទេសកម្ពុជា ២៧ទំព័រ។



**ទំនាក់ទំនង:**
រដ្ឋបាលជលផល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
#១៨៦ មហាវិថីនរោត្តម រាជធានីភ្នំពេញ ប្រទេសកម្ពុជា



© រដ្ឋបាលជលផល
រក្សាសិទ្ធគ្រប់យ៉ាង។ ការបោះពុម្ពឡើងវិញទាំងស្រុង ឬផ្នែកណាមួយសម្រាប់គោលបំណងអប់រំឬមិនរកប្រាក់ចំណេញ មិនតម្រូវឱ្យសុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិបញ្ញា ដោយគ្រាន់តែថ្លែងអំណរគុណតាមរយៈការផ្តល់ប្រភពដើមនៃរបាយការណ៍ដូចមានផ្តល់ជូនស្រាប់។ រាល់ការបោះពុម្ព ការចម្លង ឬចែកចាយសម្រាប់លក់បន្ត ឬគោលបំណងពាណិជ្ជកម្មផ្សេងទៀតត្រូវសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរដ្ឋបាលជលផល។

រាល់មតិយោបល់និងទស្សនៈ ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនអាចឆ្លុះបញ្ចាំងពីជំហររបស់រដ្ឋបាលជលផល ដៃគូ ឬអង្គការ ដែលផ្តល់មូលនិធិសម្រាប់គម្រោងនិងការបោះពុម្ពផ្សាយនោះទេ។

# សេចក្ដីសង្ខេប

ការសម្ភាសវាយតម្លៃផលនេសាទតាមបែបវិទ្យាសាស្ត្រត្រូវបានអនុវត្តរយៈពេល ៧ខែក្នុងឆ្នាំ២០២៣ ដោយមន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប (IFReDI) និងមន្ត្រីខណ្ឌរដ្ឋបាលជលផលតាមបណ្តាខេត្តគោលដៅ។ យោងលើបទពិសោធន៍អនុវត្តនៅអំឡុងឆ្នាំ២០២១-២០២២ ការសម្ភាសត្រូវបានសម្រេច ដោយគ្របដណ្តប់លើ៥៨ចំនួនភូមិ (១៥គ្រួសារអ្នកនេសាទ/ភូមិ) ដែលធ្វើអោយការប្រមូលទិន្នន័យគ្របដណ្តប់រហូតដល់៨៨៣គ្រួសារអ្នកនេសាទ តាមរយៈការជ្រើសរើសដោយចៃដន្យនៅតាមតំបន់នេសាទទាំងអស់ក្នុងការធ្វើសម្ភាសប្រមូលទិន្នន័យប្រចាំខែ។ ចំនួនសម្ភាសនេះខ្ពស់ទ្វេដងធៀបទៅនឹងចំនួនសម្ភាសនៅក្នុងឆ្នាំ២០២២ ដែលការសម្ភាសប្រចាំខែបានគ្របដណ្តប់ ចំនួន២៥ភូមិ ស្មើនឹងការសម្ភាសសរុបមានចំនួន៣៥០គ្រួសារ។

គ្រួសារអ្នកនេសាទនៅតំបន់នេសាទខ្ពង់រាបមានសមាមាត្រគ្រួសារនេសាទសកម្មខ្ពស់បំផុត ខណៈគ្រួសារអ្នកនេសាទនៅតំបន់ឆ្នេរ និងតំបន់ទំនាបលិចទឹកមានការចូលរួមក្នុងសកម្មភាពនេសាទទាបបំផុត។ លទ្ធផលនេះស្របខ្លាំងទៅនឹងផលនេសាទមធ្យមប្រចាំថ្ងៃទទួលបានពីការអង្កេតដែលរកឃើញថា ផលនេសាទខ្ពស់បំផុតមាននៅតំបន់ទន្លេសាប បន្ទាប់មកគឺផលនេសាទនៅតំបន់ខ្ពង់រាប និងតំបន់ភ្នំ។ សមត្ថភាពចាប់ក៏ត្រូវបានគេអង្កេតឃើញមានសណ្ឋានស្រដៀងគ្នាផងដែរ។

ដោយសារតែការសម្ភាសមិនបានគ្របដណ្តប់ពេញមួយឆ្នាំ នាំឱ្យលទ្ធផលមានការប្រែប្រួលតាមរដូវតិចតួចរវាងតំបន់នេសាទ។ ទោះបីជានៅខែមិថុនា កម្រិតគ្រួសារនេសាទសកម្មមានទាបបំផុត និងផលនេសាទប្រចាំថ្ងៃជាមធ្យមខ្ពស់បំផុតក៏ដោយ ក៏សូចនាករផ្សេងទៀតបង្ហាញតម្លៃមានភាពខុសគ្នាតិចតួចផងដែរ។ ចំនួនគ្រួសារដែលមានសកម្មភាពនេសាទខ្ពស់ជាងគេក្នុងអំឡុងខែសីហាដល់ខែតុលា។ ក្រុមគ្រួសារអ្នកនេសាទនៅតំបន់ទន្លេសាបមានផលនេសាទខ្ពស់បំផុតប្រចាំខែ (៩០គីឡូក្រាម/ខែ) ទោះបីជាមិនរួមបញ្ចូលទិន្នន័យខែធ្នូក៏ដោយ បន្ទាប់មកតំបន់ភ្នំ និងតំបន់ខ្ពង់រាប។ ដោយឡែកតំបន់ទំនាបលិចទឹក និងតំបន់ឆ្នេរ មានផលនេសាទតាមគ្រួសារប្រចាំខែជាមធ្យមទាបជាងគេខ្លាំង។

ការប៉ាន់ប្រមាណផលនេសាទប្រចាំខែ មានការប្រែប្រួលពីកម្រិតទាប ៤៣ ០០០តោន ក្នុងខែមិថុនាប្រមាណ ៥២ ០០០តោន ក្នុងខែកញ្ញា និង៦១ ០០០តោន ក្នុងខែតុលា និងធ្លាក់ចុះមក ៤៣ ០០០តោនវិញក្នុងខែវិច្ឆិកា។ ការខ្វះចន្លោះនៃការធ្វើសម្ភាសប្រមូលទិន្នន័យនៅរដូវប្រាំង ធ្វើឱ្យមានការពិបាកក្នុងការប៉ាន់ប្រមាណផលនេសាទសរុបសម្រាប់ឆ្នាំ២០២៣ ដោយឡែកការយកផលចាប់នៅរដូវប្រាំងឆ្នាំ២០២២ តំណាងឱ្យផលចាប់សម្រាប់ខែនានាដែលមិនបានគ្រប់ដណ្តប់នៅឆ្នាំ២០២៣ទេ ធ្វើឱ្យការប៉ាន់ប្រមាណផលនេសាទសរុបមានចំនួន ៤៨៩ ៤២៣តោន។ ការរួមចំណែកផលនេសាទតាមតំបន់នេសាទនីមួយៗសម្រាប់ខែមិថុនា ដល់ខែវិច្ឆិកា ឆ្នាំ២០២៣ គឺតំបន់ទន្លេសាបមានការរួមចំណែកខ្ពស់បំផុត (៤៨,២%) បន្ទាប់មកតំបន់ទំនាបលិចទឹក (២៦,១%) និងតំបន់ភ្នំ (១៣,២%) ជាមួយនឹងតំបន់ខ្ពង់រាប ១០,២% និងតំបន់ឆ្នេរ ២,២%។

សកម្មភាពនេសាទភាគច្រើនពាក់ព័ន្ធនឹងបុរសពេញវ័យ (៨៥,៨%) និងស្ត្រីពេញវ័យ (១១,៣%) ដោយមានការប្រែប្រួលតិចតួចរវាងតំបន់នេសាទនីមួយៗ រីឯការចូលរួមស្ត្រីពេញវ័យនៅក្នុងសកម្មភាពនេសាទខ្ពស់បំផុត គឺនៅតំបន់ទន្លេសាប (១៥,១%) និងតំបន់ទំនាបលិចទឹក (១១,២%)។ សកម្មភាពនេសាទដោយកុមារ គឺកម្រមានណាស់ ដោយក្មេងប្រុសចូលរួមក្នុងការនេសាទ ៣,១% និងក្មេងស្រី ០,៨%។ ផលនេសាទភាគច្រើនបានពីការនេសាទ

ដោយប្រើទូក (៦៩,១%) ក្រៅពីនេះជាផលនេសាទបានពីការនេសាទដោយមិនប្រើទូក។ តំបន់នេសាទ ដោយមិនប្រើទូកខ្ពស់ជាងគេ គឺតំបន់ឆ្នេរ (៩២,១%) បន្ទាប់មកតំបន់ភ្នំ (៦៦,៧%)។

ផលនេសាទភាគច្រើន គឺទទួលបានពីទីជម្រកទំនាបលិចទឹក(៣២,៩%) បន្ទាប់មកពីផ្លូវទឹកនានា(ស្ទឹង)ហូរចូលបឹងទន្លេសាទ (២៩,៥%) និងដងទន្លេមេគង្គ (១៦,៤%)។

ឧបករណ៍នេសាទសំខាន់បំផុត គឺមង ក្នុងនោះមងកាំង (៣៤,៧%) ខ្ពស់ជាងមងបណ្តែត (១១,៤%) ។ លបត្រីរួមចំណែក ១៨,៧% សំណាញ់ (៤,៤%) និងសន្ទូចរាយ (២,៧%)។

សមាមាត្រនៃផលនេសាទ ដែលបានលក់ គឺ៥៥,៥% ហើយផលនេសាទដែលនៅសល់ត្រូវបានប្រើសម្រាប់បរិភោគ (២៥,៩%) ឬសម្រាប់ការប្រើប្រាស់ផ្សេងទៀត (១៨,៥%)។ សមាមាត្រនៃផលនេសាទ ដែលបានលក់ខ្ពស់បំផុត គឺមាននៅតំបន់ទន្លេសាប (៧២,០%) និងតំបន់ទំនាបលិចទឹក (៤៦,១%)។ មានភាពខុសគ្នាតាមរដូវទាក់ទងនឹងការប្រើប្រាស់ផលនេសាទ គឺដោយសារការលក់ត្រីជាទូទៅខ្ពស់ជាងនៅដើមរដូវវស្សា ប៉ុន្តែសមាមាត្រនៃការលក់ត្រីនៅចន្លោះខែមិថុនាដល់ខែវិច្ឆិកា មានកម្រិតប្រហាក់ប្រហែលគ្នាស្ទើរតែគ្រប់តំបន់នេសាទ។

ត្រីមានប្រហែលជា៨០,៥% នៃផលនេសាទសរុប ដោយឡែកផលវារីសត្វដ៏ទៃទៀត (OAA) រួមចំណែក ១៧,៩% ហើយ OAA ភាគច្រើនមាននៅរដូវប្រាំង។ ប្រភេទត្រីដែលនេសាទបានច្រើនជាងគេទាំង២០ប្រភេទ (ផ្អែកតាមទម្ងន់ផលនេសាទ) គឺមានប្រមាណ ៧៥% នៃផលនេសាទសរុប ដែលលទ្ធផលនេះបង្ហាញពីវត្តមានប្រភេទវារីសត្វជាច្រើនសម្រាប់ជលផលទឹកសាប។ ក្នុងក្នុងចំណោម២០ប្រភេទនេះ គឺមានវារីសត្វបីប្រភេទ ដូចជាត្រីច្រកែង (*Puntioplites proctozysron* ) ក្តាមវាលស្រែ (*Somanniathelphusa sp.*) និងត្រីល្អិតចម្រុះ គឺមានបរិមាណច្រើនជាងគេប្រមាណ ២៧% នៃផលនេសាទសរុប។

អនុសាសន៍មួយចំនួន ត្រូវបានពិភាក្សាទាក់ទងនឹងការរួមបញ្ចូលគ្នានៃលទ្ធផលដែលទទួលបានពីការវាយតម្លៃផលនេសាទទឹកសាប (CAS) ទៅក្នុងស្ថិតិផលនេសាទថ្នាក់ជាតិ និងការផ្ទេរការប្រមូលទិន្នន័យ និងធនធានដល់មន្ត្រីខណ្ឌរដ្ឋបាលជលផល។ IFReDI ជាអង្គភាពថ្នាក់កណ្តាលបន្តផ្តល់ជំនួយការបច្ចេកទេសលើការគ្រប់គ្រងទិន្នន័យ វិធីសាស្ត្រនៃការប្រមូលទិន្នន័យតាមសំណាកគំរូ និងការវិភាគទិន្នន័យ។

## មាតិកា


សេចក្តីថ្លែងអំណរគុណ.......................................................................................................2

សេចក្តីសង្ខេប .................................................................................................................3

តារាងពាក្យបំព្រួញ ..........................................................................................................6

១. សេចក្តីផ្តើមនិងវិធីសាស្ត្រស្រាវជ្រាវ ...............................................................................8

២. តារាងស្ថិតិនិងលទ្ធផល................................................................................................9

៣.ការពិភាក្សានិងអនុសាសន៍ ........................................................................................27

៣.១ ការពិភាក្សា ..............................................................................................................27

៣.២ អនុសាសន៍................................................................................................................31

# តារាងពាក្យបំព្រួញ

| | | |
|---|---|---|
| AP | Aquatic Plants | រុក្ខជាតិ |
| CAPFISH | Cambodia Programme for Sustainable and Inclusive Growth in the Fisheries Sector | កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន៖ សមាសភាគការនេសាទ |
| CAS | Catch Assessment Survey | ការវាយតម្លៃផលនេសាទទឹកសាប |
| CPUE | Catch per Unit of Effort | សមត្ថភាពចាប់ក្នុងមួយខ្នាតឯកត្តា |
| DFMP | Dai Fisheries Monitoring Programme | កម្មវិធីតាមដានផលចាប់ដោយឧបករណ៍ដាយ |
| DPFIC | Department of Planning, Finance and International Cooperation | នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ |
| EU | European Union | សហភាពអឺរ៉ុប |
| ε% | Relative Standard Error | លំអៀងស្តង់ដារប្រៀបធៀប |
| FAO | Food and Agriculture Organisation | អង្គការស្បៀងនិងកសិកម្ម |
| FH | Fishing Household | គ្រួសារនេសាទ |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| FiAC | Fisheries Administration Cantonment | ខណ្ឌរដ្ឋបាលជលផល |
| GIS | Geographic Information System | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| HCI | Household Catch Interview | ការសម្ភាសផលចាប់តាមគ្រួសារ |
| HH | Household | គ្រួសារ |
| HSI | Household Selection Interview | ការសម្ភាសជ្រើសរើសគ្រួសារ |
| IFReDI | Inland Fisheries Research and Development Institute | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MRC | Mekong River Commission | គណៈកម្មការទន្លេមេគង្គ |

| | | |
|---|---|---|
| MT | Metric Ton | មួយតោន (១000គីឡូក្រាម) |
| NA | Not Applicable | គ្មានព័ត៌មាន |
| nei | not elsewhere included | គ្មានក្នុងក្រុមដទៃ |
| NF | Non-fish (for species codes) | មិនមែនត្រី (កូដសម្គាល់ប្រភេទ) |
| NIS | National Institute for Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| OAA | Other Aquatic Animals | វារីសត្វដទៃទៀត |
| OAO | Other Aquatic Organisms | វារីសារពាង្គកាយដទៃទៀត |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SES | Socio-Economic Survey | ការអង្កេតសេដ្ឋកិច្ច-សង្គម |
| USD | United States Dollars | ដុល្លារអាមេរិក |
| WSIM | Working Group on Statistics and Information Management | ក្រុមការងារគ្រប់គ្រងស្ថិតិនិងព័ត៌មាន |

## ១. សេចក្តីផ្តើមនិងវិធីសាស្ត្រស្រាវជ្រាវ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប (IFReDI) ក្រោមជំនួយបច្ចេកទេសនៃកម្មវិធីជំរុញកំណើន វិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ននៃអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO CAPFISH) ក្រោមការគាំទ្រថវិការបស់សហភាពអឺរ៉ុប (EU) បានអនុវត្តការវាយតម្លៃផលនេសាទទឹកសាបតាមបែបវិទ្យាសាស្ត្រ (CAS) ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣។ ការវាយតម្លៃប្រើប្រាស់វិធីសាស្ត្រនៃការសម្ភាសតាមគ្រួសារអ្នកនេសាទប្រចាំខែតាមបែបរំលឹកឡើងវិញក្នុងរយៈពេល៥ថ្ងៃកន្លងទៅ។ គោលបំណងនៃការវាយតម្លៃនេះ គឺដើម្បីទទួលបានព័ត៌មានកាន់តែប្រសើរអំពីផលនេសាទ និងសមត្ថភាពចាប់ដោយគ្រួសារនេសាទខ្នាតតូចក្នុងប្រទេសកម្ពុជា ដើម្បីរួមចំណែកក្នុងការបង្កើតវិធីសាស្ត្រតាមដានផលនេសាទមួយ និងដើម្បីនិរន្តរភាពនៃការអនុវត្តការវាយតម្លៃផលនេសាទទឹកសាបនៅតាមខណ្ឌរដ្ឋបាលជលផលក្រោមការគាំទ្របច្ចេកទេសដោយ IFReDI។

ការប្រមូលទិន្នន័យនៅឆ្នាំ២០២៣ បានធ្វើឡើងចាប់ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣។ ខ្លឹមសារនៃរបាយការណ៍ប្រចាំឆ្នាំនេះ គឺផ្តោតលើរបាយការណ៍ស្ថិតិប្រចាំខែក្នុងឆ្នាំ២០២៣។ របាយការណ៍ស្ថិតិ បង្ហាញទិន្នន័យតាមតំបន់នេសាទនីមួយៗ ដែលការចែកតំបន់គឺខុសពីតំបន់នេសាទស្ថិតក្រោមអធិការដ្ឋាននៃរដ្ឋបាលជលផល។ ការបែងចែកខេត្តតាមតំបន់នេសាទ គឺផ្អែកលើចំនួនសរុបនៃគ្រួសារនេសាទនៅទីជនបទ (ជំរឿនប្រជាជនឆ្នាំ២០១៩) ដោយវិទ្យាស្ថានជាតិស្ថិតិ និងសមាមាត្រនៃគ្រួសារនេសាទទទួលបានពីការសម្ភាសន៍ជ្រើសរើសគ្រួសារនេសាទ (HSI) ដោយ IFReDI។ ការបែងចែកខេត្តតាមតំបន់នេសាទជាមួយនឹងចំនួនគ្រួសារ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធ១។



ការពិពណ៌នាអំពីវិធីសាស្ត្រការប្រមូល និងវិភាគទិន្នន័យផលនេសាទទឹកសាប អាចរកបានតាមរយៈរដ្ឋបាលជលផល (FiA) ឆ្នាំ២០២១៖ ឯកសារណែនាំការវាយតម្លៃផលនេសាទទឹកសាបតាមបែបវិទ្យាសាស្ត្រក្នុងប្រទេសកម្ពុជា ប្រើការសម្ភាសតាមបែបរំលឹកឡើងវិញ ចងក្រងដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៤៧ទំព័រ។

ផលនេសាទប៉ាន់ប្រមាណសរុបនៅក្នុងរបាយការណ៍នេះ គឺគណនាដោយប្រើសមាមាត្រគ្រួសារនេសាទ តាមរយៈការជ្រើសរើសគ្រួសារនេសាទដោយចៃដន្យនៅក្នុងការសម្ភាសន៍ HIS។ លទ្ធផលបានពីការគណនានេះតំណាងអោយសមាមាត្រគ្រួសារនេសាទតាមតំបន់នេសាទនីមួយៗ ហើយសមាមាត្រតំណាងគ្រួសារតាមតំបន់នេសាទត្រូវដាក់បញ្ចូលជាមួយនឹងចំនួនគ្រួសារសរុបនៅទីជនបទតាមតំបន់នេសាទនីមួយៗពីទិន្នន័យជំរឿនប្រជាជន នៃវិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០១៩។ មេគុណសកម្មភាពនេសាទ ដែលតំណាងឱ្យសមាមាត្រនៃគ្រួសារនេសាទសកម្មនៅតាមខែ ត្រូវបានប៉ាន់ប្រមាណចេញពីសមាមាត្រនៃគ្រួសារ ដែលត្រូវបានធ្វើនេសាទនៅក្នុងការសម្ភាសតាមដានផលចាប់តាមគ្រួសារ។

ការប៉ាន់ប្រមាណសមត្ថភាពចាប់ក្នុងមួយខ្នាតឯកតា (CPUE) គឺជាតម្លៃមធ្យម (mean) នៃផលនេសាទតាមគ្រួសារអ្នកនេសាទប្រចាំថ្ងៃ និងប្រចាំខែ ដែលបានប្រើសម្រាប់ការគណនាផលនេសាទសរុប រួមជាមួយនឹងការបង្ហាញលំអៀងស្តង់ដារប្រៀបធៀប (ε%)។ តម្លៃ ε% ត្រូវបានប្រើដើម្បីចង្អុលបង្ហាញអំពីភាពត្រឹមត្រូវបែបស្ថិតិនៃការប៉ាន់

ប្រមាណផលចាប់មធ្យម។ ប្រសិនបើតម្លៃ ៩% ខ្ពស់ជាង ៣០% គឺបង្ហាញពីកម្រិតមិនត្រឹមត្រូវតាមបែបស្ថិតិ[1] ដែលលទ្ធផលនេះអាចបណ្ដាលមកពីបម្រែបម្រួលទិន្នន័យខ្ពស់ រឺក៏មកពីទំហំសំណាកទាប ហើយតម្លៃ ៩% ខ្ពស់បែបនេះមិនអាចប្រើតំណាងអោយតម្លៃពិតនៃផលនេសាទមធ្យមបានឡើយ។ តម្លៃ ៩% មានចង្អុលបង្ហាញយ៉ាងច្បាស់នៅក្នុងតារាងក្នុងរបាយការណ៍នេះ។

## ២. តារាងស្ថិតិនិងលទ្ធផល

ដោយសារជាឆ្នាំចុងក្រោយនៃការអនុវត្ត CAS នៅចុងឆ្នាំ២០២២ មានការសម្រេចយកគោលដៅប្រមូលទិន្នន័យពីសំណាកគំរូអោយបានច្រើនបំផុតដែលអាចអនុវត្តទៅបាន ចំនួនសំណាកគំរូបានគ្របដណ្ដប់លើតំបន់នេសាទទាំងអស់តាមសមាមាត្រនៃសារៈសំខាន់នៃតំបន់នេសាទនីមួយៗ ដើម្បីទទួលបានការប៉ាន់ប្រមាណដែលមានលក្ខណៈតំណាង និងអាចទុកចិត្តបានដល់សូចនាករផ្សេងៗគ្នា។ ការប្រមូលទិន្នន័យគ្របដណ្ដប់ចាប់ពីខែមិថុនាដល់ខែធ្នូ ឆ្នាំ២០២៣ បង្ហាញថាចំនួនភូមិ និងគ្រួសារ ដែលត្រូវបានដាក់បញ្ចូលជាសំណាកគំរូចៃដន្យ មានចំនួនប្រហែលគ្នា (ថេរ) លើកលែងតែ ២ខែចុងក្រោយនៃការសម្ភាស (តារាងទី១)។ ការកាត់បន្ថយការសម្ភាសនៅខែវិច្ឆិកា និងខែធ្នូ គឺដោយសារភាពមមាញឹកនៃការងារក្នុងវិស័យផ្សេងទៀត និងជាពិសេសការកាត់បន្ថយថវិកាសម្រាប់អនុវត្តនៅខែធ្នូ និងពេលវេលាសម្រាប់ចុះអនុវត្តសកម្មភាពមានខ្លី និងការបិទបញ្ជីគណនីនៅដើមខែធ្នូ។

នៅក្នុងដែនកំណត់នៃមន្ត្រី និងចំនួនថ្ងៃចុះអនុវត្តការងារនៅទីវាល ក្នុងអំឡុងពេលនៃការអនុវត្តឆ្នាំ២០២៣ IFReDI បានរក្សានូវចំនួនសំណាកគ្រួសារចៃដន្យខ្ពស់។ តម្លៃខ្ពស់ជាង ១០០% បង្ហាញថា ការសម្ភាសគ្រួសារត្រូវបានធ្វើឡើងច្រើនជាងការគ្រោងទុក ភាគច្រើនក្នុងករណីមានគ្រួសាររើចាកចេញពីភូមិគោលដៅ។ ជាក់ស្តែងនៅខែធ្នូ ការសម្ភាសបានគ្របដណ្ដប់តែ ៦ភូមិប៉ុណ្ណោះសម្រាប់តំបន់ទន្លេសាប ដូចនេះសំណាកគ្រួសារក្នុងភូមិនីយមួយៗមានចំនួនច្រើនជាងមុន ដើម្បីបំពេញបន្ថែមដល់ភូមិ ដែលមិនបានគ្របដណ្ដប់ នាំឱ្យមានការសម្ភាសបានកើនឡើង ៥០% នៃចំនួនគ្រួសារគោលដៅ។ មូលហេតុចម្បងនៃការមិនសម្រេចបាននូវការគ្របដណ្ដប់ ១០០% គឺនៅពេលមិនអាចរកឃើញគ្រួសារក្នុងអំឡុងពេលសម្ភាស ប៉ុន្តែគ្រួសារទាំងនោះត្រូវបន្តរក្សាទុកក្នុងការសម្ភាស។

**តារាងទី១.** សំណាកភូមិ និងគ្រួសារ ជាមួយនឹងសមាមាត្រនៃគ្រួសារគោលដៅតាមតំបន់នេសាទ ខែមិថុនាដល់ខែធ្នូ ឆ្នាំ២០២៣

| តំបន់នេសាទ | ចំនួនភូមិ | | | | | | |
|---|---|---|---|---|---|---|---|
| | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ឆ្នេរ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | |
| ទន្លេសាប | ២០ | ២០ | ២០ | ២០ | ២០ | ១៦ | ៥ |
| ទំនាបលិចទឹក | ១៧ | ១៧ | ១៧ | ១៧ | ១៧ | ១៧ | |
| ខ្ពង់រាប | ១០ | ១០ | ១០ | ១០ | ១០ | ១០ | |
| ភ្នំ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៣ |
| សរុប | **៥៦** | **៥៦** | **៥៦** | **៥៦** | **៥៦** | **៥២** | **៨** |

[1]សម្រាប់របាយការណ៍ស្ថិតិជាតិ គោលការណ៍ Rule of Thumb កំណត់ថាប្រសិនបើតម្លៃ ៩% ខ្ពស់ជាង ៣០% គេមិនគួររាយការណ៍ចំនួនមធ្យមនោះទេ ហើយគេរាយការណ៍តែតម្លៃណា ដែលមានតម្លៃ ៩% ទាបជាង ២៥% ដែលជាតម្លៃមានសុពលភាពបែបស្ថិតិ។ របាយការណ៍នេះដាក់បញ្ចូលតម្លៃប៉ាន់ប្រមាណទាំងអស់ ដោយមានរួមបញ្ចូលតម្លៃ ៩% ដើម្បីចង្អុលបង្ហាញអំពីភាពត្រឹមត្រូវបែបស្ថិតិដល់តម្លៃប៉ាន់ប្រមាណ។

| តំបន់នេសាទ | ចំនួនគ្រួសារ | | | | | | |
|---|---|---|---|---|---|---|---|
| | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ឆ្នេរ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ | |
| ទន្លេសាប | ២៨៨ | ១៩៤ | ២៩៩ | ៣០០ | ២៩៩ | ២១៧ | ១០៩ |
| ទំនាបលិចទឹក | ២៥៥ | ២៥៨ | ២៥៣ | ២៥៧ | ២៥៤ | ២៤៦ | |
| ខ្ពង់រាប | ១៥៩ | ១៤៩ | ១៥០ | ១៥១ | ១៥១ | ១៤២ | |
| ភ្នំ | ៩០ | ៨៩ | ៩០ | ៩០ | ៩១ | ៧៤ | ៤៥ |
| **សរុប** | **៨៣៧** | **៨៣៥** | **៨៣៧** | **៨៤៣** | **៨៤០** | **៧២៤** | **១៥៤** |

| តំបន់នេសាទ | គ្រួសារគោលដៅ ដែលត្រូវបានសម្ភាស (%) | | | | | | |
|---|---|---|---|---|---|---|---|
| | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ឆ្នេរ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | |
| ទន្លេសាប | ៩៦ | ៩៨ | ៩៩,៧ | ១០០ | ៩៩,៧ | ៩០,៤ | ១៤៥,៣ |
| ទំនាបលិចទឹក | ១០០ | ១០១,២ | ៩៩,២ | ១០០,៨ | ៩៩,៦ | ៩៦,៥ | |
| ខ្ពង់រាប | ១០៦ | ៩៩,៣ | ១០០ | ១០០,៧ | ១០០,៧ | ៩៤,៧ | |
| ភ្នំ | ១០០% | ៩៨,៩ | ១០០ | ១០០ | ១០១,១ | ៨២,២ | ១០០ |
| **សរុប** | **៩៩,៦** | **៩៩,៤** | **៩៩,៦** | **១០០,៤** | **១០០** | **៩២,៨** | **១២៨,៣** |




**ក្រាហ្វិកទី១**. ភូមិដែលត្រូវបានជ្រើសរើសដោយចៃដន្យ គ្របដណ្តប់ដោយ CAS ក្នុងអំឡុងឆ្នាំ២០២៣

ភូមិគោលដៅសម្រាប់ CAS ក្នុងកំឡុងឆ្នាំ២០២៣ បង្ហាញក្នុងក្រាហ្វិកទី១។ របាយនៃការបែងចែកភូមិ ដែលត្រូវបានជ្រើសរើសដោយចៃដន្យ និងតំបន់នេសាទ មិនស្របតាមការបែងចែកខេត្តតាមអធិការដ្ឋានជលផលទេ ប៉ុន្តែការបែងចែកនេះផ្អែកទៅតាមលក្ខណៈនេសាទនៃភូមិទាំងនោះ។ ខុសពីអ្វីការអនុវត្តនៅឆ្នាំ២០២២ កំណត់ត្រាសម្ភាសនៅខេត្តកំពង់ស្ពឺត្រូវបានដាក់បញ្ចូលទៅក្នុងតំបន់ភ្នំ ដើម្បីបំពេញបន្ថែមកំណត់ត្រាសម្ភាសពីខេត្តត្បូងឃ្មុំ។ ដូចគ្នានេះដែរ ខេត្តរតនគិរីត្រូវបានដាក់រួមបញ្ចូលទៅក្នុងតំបន់ខ្ពង់រាប និងខេត្តកំពង់ចាមត្រូវបានបញ្ចូលទៅក្នុងតំបន់ទំនាបលិចទឹក ដោយសារការកែសម្រួលនេះធ្វើឡើងដើម្បីឆ្លុះបញ្ចាំងអោយកាន់តែច្បាស់អំពីទីជម្រកនៃដែននេសាទ ដែលមានតាមតំបន់នេសាទ និងប្រភេទនៃនេសាទ។

ភាពខុសគ្នាតាមរដូវសម្រាប់សូចនាករផ្សេងៗគ្នាបានបង្ហាញក្នុងតារាងទី២ ជាមួយនឹងផលនេសាទប្រចាំថ្ងៃខ្ពស់បំផុតមាននៅខែមិថុនា នៅគ្រប់តំបន់នេសាទទាំងអស់ លើកលែងតែគ្រួសារតំបន់ឆ្នេរ។ លទ្ធផលនេះឆ្លុះបញ្ចាំងពីផលនេសាទពីជម្រកនេសាទគោលដៅ ដែលទទួលរងផលប៉ះពាល់ដោយលក្ខខណ្ឌគ្រោះរាំងស្ងួត។ សមាមាត្រនៃគ្រួសារនេសាទមានខ្ពស់បំផុតនៅចន្លោះខែសីហាដល់ខែតុលា ប៉ុន្តែសមាមាត្រនៃគ្រួសារនេសាទនៅតំបន់ភ្នំ មានកម្រិតខ្ពស់បំផុត នៅខែវិច្ឆិកា និងខែធ្នូ។ ជារួម គ្រួសារនៅតំបន់ខ្ពង់រាបមានសមាមាត្រនៃគ្រួសារនេសាទសកម្មខ្ពស់បំផុត (៧២,៨%)។ សមត្ថភាពចាប់មាននិន្នាការកើនឡើងខ្ពស់ក្នុងខែកក្កដាដល់ខែតុលា។ ប៉ុន្តែកង្វះទិន្នន័យនៅមុនខែមិថុនាធ្វើឱ្យពិបាកក្នុងការបកស្រាយការប្រែប្រួលនេះ។ ទិន្នន័យទាំងនេះមិនបានកំណត់ច្បាស់អំពីទំនាក់ទំនងរវាងការប្រែប្រួលអំពីលំហូរ ឬទឹកជំនន់តាមរដូវឡើយ។ សមត្ថភាពចាប់សម្រាប់បឹងទន្លេសាប គឺខ្ពស់ខ្លាំងនៅខែធ្នូ ប៉ុន្តែលទ្ធផលនេះតំណាងអោយតែភូមិដែលបានសម្ភាសចំនួន៥ប៉ុណ្ណោះ។

**តារាងទី២.** គ្រួសារនេសាទសកម្ម ថ្ងៃធ្វើនេសាទប្រចាំខែ និងផលនេសាទតាមគ្រួសារ (គ.ក្រ) ប្រចាំខែ ជាមធ្យម តាមតំបន់នេសាទនីមួយៗ

| សមាមាត្រនៃគ្រួសារនេសាទសកម្ម(%) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **តំបន់នេសាទ** | **មិថុនា** | **កក្កដា** | **សីហា** | **កញ្ញា** | **តុលា** | **វិច្ឆិកា** | **ធ្នូ** | **២០២៣** |
| ឆ្នេរ | ២២,២ | ៤៨,៩ | ៥១,១ | ៥៣,៣ | ៤៨,៩ | ៥៣,៣ | | **៤៦,៣** |
| ទំនាបលិចទឹក | ៣០,២ | ៤៣,៦ | ៥១ | ៥៨ | ៥៦,៧ | ៥៤,៣ | | **៤៨,៩** |
| ខ្ពង់រាប | ៤៥,៩ | ៦៣,៨ | ៨២ | ៨៦,៨ | ៨៦,១ | ៧៣,៩ | | **៧២,៨** |
| ទន្លេសាប | ៤៥,៨ | ៥១,៤ | ៥១,៨ | ៧១,៧ | ៧៥,៦ | ៦០,៣ | ៧៤,៨ | **៦០,៥** |
| ភ្នំ | ៣៨,៩ | ៥១,៧ | ៦១,១ | ៦៤,៤ | ៦៨,១ | ៨៥,១ | ៨២,២ | **៦២,៦** |
| **សរុប** | **៣៩,១** | **៥១,១** | **៥៧,៩** | **៦៨,៤** | **៦៩,៥** | **៦៣** | **៧៦,៨** | **៥៨,៧** |

| ផលនេសាទតាមគ្រួសារប្រចាំថ្ងៃជាមធ្យម | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **តំបន់នេសាទ** | **មិថុនា** | **កក្កដា** | **សីហា** | **កញ្ញា** | **តុលា** | **វិច្ឆិកា** | **ធ្នូ** | **២០២៣** |
| ឆ្នេរ | ២,៣២ | ២,៦១ | ២,០៥ | ២,២៤ | ២,៤៦ | ២,៣៦ | | **២,៣៤** |
| ទំនាបលិចទឹក | ៣,៣១ | ៣.១៥ | ៣,០២ | ៣,៣០ | ២,២៩ | ២,៥២ | | **២,៩០** |
| ខ្ពង់រាប | ៦,០៧ | ៤,១១ | ៤,១៦ | ២,៩០ | ៣,១៦ | ២,៤២ | | **៣,៦៤** |
| ទន្លេសាប | ៦,២៣ | ៥,៦៤ | ៤,៤៤ | ៤,៩៥ | ៥,៤០ | ៤,៣២ | ៤,៨៧ | **៥,១៣** |
| ភ្នំ | ៥,៤៧ | ២,៨០ | ៤,១៧ | ៤,៣៨ | ៣,៩១ | ៣,៥២ | ២,១៤ | **៣,៧៨** |
| **សរុប** | **៥,៣១** | **៤,១៨** | **៣,៨៥** | **៣,៨៩** | **៣,៨៧** | **៣,១៦** | **៤,០៧** | **៣,៩៧** |

| ថ្ងៃធ្វើនេសាទតាមគ្រួសារប្រចាំខែជាមធ្យម | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **តំបន់នេសាទ** | **មិថុនា** | **កក្កដា** | **សីហា** | **កញ្ញា** | **តុលា** | **វិច្ឆិកា** | **ធ្នូ** | **២០២៣** |
| ឆ្នេរ | ១២,៦ | ១១,៧ | ១៤,៦ | ១៣ | ១៦,១ | ១៤,៨ | | **១៣,៩** |
| ទំនាបលិចទឹក | ១៦,៩ | ១៣ | ១៤,១ | ១២,៨ | ១៣,៥ | ១៥,១ | | **១៤** |
| ខ្ពង់រាប | ២០,៨ | ១៦,៩ | ១៧,៥ | ១៤,៩ | ១៦,១ | ១៤ | | **១៦,៤** |
| ទន្លេសាប | ១៥,៥ | ១៦,៣ | ១៦,៧ | ១៦,៨ | ១៩,២ | ១៦,៣ | ២៤,៥ | **១៧,៦** |
| ភ្នំ | ១៦,១ | ១៦ | ១៨,៣ | ១៧,១ | ១៨,១ | ១៨,៩ | ១៣,៨ | **១៧,២** |
| **សរុប** | **១៧** | **១៥,៣** | **១៥,២** | **១៥,២** | **១៦,៩** | **១៥,៧** | **២១,៤** | **១៦,២** |

| ផលនេសាទតាមគ្រួសារប្រចាំខែជាមធ្យម (គ.ក្រ) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **តំបន់នេសាទ** | **មិថុនា** | **កក្កដា** | **សីហា** | **កញ្ញា** | **តុលា** | **វិច្ឆិកា** | **ធ្នូ** | **2023** |
| ឆ្នេរ | ២៩,៣ | ៣០,៧ | ២៩,៩ | ២៩,២ | ៣៩,៥ | ៣៤,៨ | | **៣២,៦** |
| ទំនាបលិចទឹក | ៥៥,៩ | ៤០,៩ | ៤២,៤ | ៤២,២ | ៣០,៩ | ៣៨ | | **៤០,៧** |
| ខ្ពង់រាប | ១២៦,២ | ៦៩,៦ | ៧២,៦ | ៤៣,២ | ៥០,៨ | ៣៤ | | **៥៩,៧** |
| ទន្លេសាប | ៩៦,៨ | ៩១,៨ | ៧៤,២ | ៨៣,២ | ១០៣,៦ | ៧០,៣ | ១១៩,៦ | **៩០,៤** |
| ភ្នំ | ៨៨,២ | ៤៤,៧ | ៧៦,៥ | ៧៤,៨ | ៧០,៧ | ៦៦,៣ | ២៩,៥ | **៦៥** |
| **សរុប** | **៩០,២** | **៦៣,៩** | **៦២,៧** | **៥៩,២** | **៦៥,១** | **៤៩,៦** | **៨៧** | **៦៤,៥** |

ផលនេសាទតាមគ្រួសារប្រចាំខែជាមធ្យម គឺមានការប្រែប្រួលតាមការនេសាទ និងសមត្ថភាពចាប់ក្នុងមួយខ្នាតនៃឯកត្តា (CPUE) ប៉ុន្តែផលនេសាទខ្ពស់ពីបន់ភ្នំ គឺមិនមានលទ្ធផលដូចបានរំពឹងទុកណាផ្សេងទៀតឡើយ។ គ្រួសារនៅតំបន់ទន្លេសាបមានផលនេសាទមធ្យមប្រចាំថ្ងៃ និងថ្ងៃនេសាទសកម្មខ្ពស់បំផុត។ យ៉ាងណាមិញ គ្រួសារនៅតំបន់ខ្ពង់រាបមានថ្ងៃនេសាទប្រចាំខែជាមធ្យមខ្ពស់បំផុតនៅខែមិថុនា (២០,៨ថ្ងៃ)។ ចំនួនថ្ងៃនេសាទនេះមិនបានចាត់ទុកថាច្រើនសម្រាប់ចំនួនថ្ងៃនេសាទមធ្យមប្រចាំខែ ដែលខ្ពស់បំផុតសម្រាប់គ្រួសារនៅតំបន់ទន្លេសាបនៅក្នុងខែធ្នូនោះទេ ពីព្រោះវាមិនបានតំណាងអោយតំបន់ទន្លេសាបទាំងមូល។

ទិន្នន័យនេះ គឺត្រូវគ្នាទៅនឹងផលនេសាទ និងការពឹងផ្អែកលើការនេសាទដូចដែលបានរំពឹងទុក ដែលជាទូទៅសមត្ថភាពចាប់ និងទិន្នផលមានកម្រិតទាបសម្រាប់គ្រួសារនៅតំបន់ឆ្នេរនិងទំនាបលិចទឹក និងមានតម្លៃខ្ពស់ជាងសម្រាប់តំបន់ខ្ពង់រាបនិងទន្លេសាប។

ការប៉ាន់ប្រមាណសរុបផលនេសាទនៅក្នុងតារាងទី៣ ត្រូវបានយកចេញពីរបាយការណ៍ស្ថិតិប្រចាំខែ ដោយរបាយការណ៍នេះតំណាងឱ្យទិន្នន័យរយៈពេល ៧ខែ។ ប៉ុន្តែការប៉ាន់ប្រមាណក្នុងខែធ្នូ ដែលផ្អែកលើទិន្នន័យតែចំនួន៨ភូមិ គឺមិនត្រូវចាត់ទុកថាជាតំណាងឱ្យស្ថានភាពទាំងមូលបានត្រឹមត្រូវឡើយ។ ការប៉ាន់ប្រមាណផលនេសាទសរុបសម្រាប់ឆ្នាំ២០២៣ ត្រូវបានគណនាដោយការបូកបន្ថែមសម្រាប់រយៈពេល១២ខែ ដោយផ្អែកទៅលើមូលដ្ឋានទិន្នន័យជាមធ្យមនៃផលនេសាទនៅចន្លោះខែមិថុនាដល់ខែវិច្ឆិកា។

**តារាងទី៣.** ផលនេសាទប៉ាន់ប្រមាណសរុប (តោន) តាមតំបន់នេសាទ និងតាមខែនីមួយៗ

| តំបន់នេសាទ | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|
| ឆ្នេរ | ៤៦៣ | ៩៥៨ | ១.០៨៣ | ៩៤៤ | ១.៥២៥ | ១.២៥៨ | |
| ទំនាបលិចទឹក | ១០.២២៣ | ១៣.០៩៤ | ១៣.៧៤២ | ១៤.៣៣៣ | ១០.៩៦៩ | ១៣.០៨៣ | |
| ខ្ពង់រាប | ៦.៥១៨ | ៥.៦៨៧ | ៦.៤៧១ | ៣.៩៨៧ | ៤.៨៧២ | ២.៧៥៣ | |
| ទន្លេសាប | ២១.៣៣១ | ២១.៦៧២ | ១៧.៥៨៣ | ២៤.៣៧៩ | ៣៦.៣៤៥ | ១៨.០២៧ | ៣៦.៤១១ |
| ភ្នំ | ៤.៥៣០ | ៣.១៧១ | ៧.០៣៥ | ៨.០៨៩ | ៧.២៦៨ | ៧.៩៦០ | ៣.៦៣៧ |
| **សរុប** | **៤៣.០៦៥** | **៤៤.៥៨២** | **៤៥.៩១៤** | **៥១.៧៣២** | **៦០.៩៧៩** | **៤៣.០៨១** | **៤០.០៤៨** |

| តំបន់នេសាទ | សរុប ៦ខែ | ផលនេសាទប្រចាំខែជាមធ្យម (តោន) | សរុបឆ្នាំ២០២៣ | %សរុប |
|---|---|---|---|---|
| ឆ្នេរ | ៦.២៣១ | ១.០៣៩ | ១២.៤៦២ | **២,២** |
| ទំនាបលិចទឹក | ៧៥.៤៤៤ | ១២.៥៧៤ | ១៥០.៨៨៨ | **២៦,១** |
| ខ្ពង់រាប | ៣០.២៨៨ | ៥.០៤៨ | ៦០.៥៧៦ | **១០,៥** |
| ទន្លេសាប | ១៣៩.៣៣៧ | ២៣.២២៣ | ២៧៨.៦៧៤ | **៤៨,២** |
| ភ្នំ | ៣៨.០៥៣ | ៦.៣៤២ | ៧៦.១០៦ | **១៣,២** |
| **សរុប** | **២៨៩៣៥៣** | **៤៨.២២៦** | **៥៧៨.៧០៦** | |

ដោយសារតែទិន្នន័យគ្របដណ្តប់មិនគ្រប់គ្រាន់ក្នុងអំឡុងពេលនៃរដូវប្រាំង ផលនេសាទមធ្យមប្រចាំខែដែលត្រូវបានប្រើសម្រាប់ការប៉ាន់ប្រមាណផលនេសាទសរុប គឺហាក់ដូចជាកើនឡើងបើប្រៀបធៀបទៅនឹងទិន្នន័យឆ្នាំ២០២២ ដែលជាមធ្យមសម្រាប់ខែមេសាដល់ខែឧសភា គឺ៣៣.៣៥០តោន។ ផលនេសាទសរុបប៉ាន់ប្រមាណខ្ពស់បំផុតត្រូវបានគេសង្កេតឃើញនៅតំបន់ទន្លេសាប បន្ទាប់មកគឺតំបន់ទំនាបលិចទឹក រីឯតំបន់ខ្ពង់រាប និងតំបន់ភ្នំមានតម្លៃប្រហាក់ប្រហែលគ្នា ខណៈដែលតំបន់ឆ្នេររួមចំណែកតិចតួចបំផុតត្រឹមតែ ២,២% ប៉ុណ្ណោះ ទៅនឹងផលនេសាទសរុប។

ការចូលរួមក្នុងការធ្វើនេសាទ (តារាងទី៤) បង្ហាញថា បុរសពេញវ័យមានការចូលរួមច្រើនក្នុងសកម្មភាពនេសាទ រហូតដល់ ៨៥% នៃសកម្មភាពនេសាទ។ ការចូលរួមស្ត្រីពេញវ័យមានការថយចុះគួរឱ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងបុរស ប៉ុន្តែវាមានកម្រិតខ្ពស់បំផុតនៅក្នុងតំបន់បឹងទន្លេសាប (១៥,១%) បន្ទាប់មកតំបន់ទំនាបលិចទឹក (១១,២%)។ តំបន់នេសាទផ្សេងទៀត ការចូលរួមដោយស្ត្រីពេញវ័យ គឺប្រហាក់ប្រហែលគ្នា នៅចន្លោះពី៧-៨%។ ក្មេងប្រុសមានកម្រិតនៃការចូលរួមខ្ពស់ជាងបន្តិចបើធៀបនឹងក្មេងស្រី ដែលមាន ៤,១% សម្រាប់ក្មេងប្រុស និង០,៧% សម្រាប់ក្មេងស្រី ក៏ប៉ុន្តែភាគរយទាំងក្មេងប្រុស និងក្មេងស្រី គឺទាបជាងការចូលរួមរបស់អ្នកនេសាទជាស្ត្រីពេញវ័យ។ ដោយឡែកទិន្នន័យអំពីចំនួនអ្នកនេសាទសរុបជាក់លាក់មិនអាចរកបាននៅឡើយ។

**តារាងទី៤.** សមាមាត្រនៃថ្ងៃធ្វើនេសាទ តាមសកម្មភាពនេសាទ[2] បង្ហាញពីទំនាក់ទំនងនឹងមនុស្សពេញវ័យ បុរស ស្ត្រី និងកុមារ

| តំបន់នេសាទ | ស្ត្រីពេញវ័យ (%) | បុរសពេញវ័យ(%) | ក្មេងស្រី(%) | ក្មេងប្រុស(%) |
|---|---|---|---|---|
| ឆ្នេរ | ៧,២ | ៥៩ | ០,៧ | ៤,១ |
| ទំនាបលិចទឹក | ១១,២ | ៩២,២ | ០,៦ | ១,៥ |
| ខ្ពង់រាប | ៧,៨ | ៧៤,២ | ០,៤ | ៣,១ |
| ទន្លេសាប | ១៥,១ | ៨៨,៣ | ០,៧ | ៤,១ |
| ភ្នំ | ៧,១ | ៩៤,៧ | ១,៨ | ២,៨ |
| **សរុប** | **១១,៣** | **៨៥,៨** | **០,៨** | **៣,១** |

ការចូលរួមអតិបរមា តាមភេទ និងក្រុមអាយុនីមួយៗ គឺ១០០% សម្រាប់តំបន់នេសាទនីមួយៗ ប្រសិនបើពួកគេធ្វើការនេសាទនៅគ្រប់ថ្ងៃនេសាទ នោះចំនួនសរុបសម្រាប់តំបន់នេសាទនីមួយៗអាចខ្ពស់ជាង ១០០%។

យោងតាមតារាងទី៥ ការប្រើប្រាស់ទូកសម្រាប់ធ្វើនេសាទខុសប្លែកគ្នាខ្លាំងនៅតាមតំបន់ ខេត្តតំបន់ឆ្នេរមានសមាមាត្រទាបបំផុតនៃផលនេសាទដោយប្រើទូក ដោយជាង ៩២,១% នៃផលនេសាទបានមកពីការនេសាទមិនប្រើទូក បន្ទាប់មកតំបន់ភ្នំមាន ៦៦,៧% និងទំនាបលិចទឹក[3] (៥៣,៥%) នៃផលនេសាទបានមកដោយប្រើទូក។ ទូកប្រើម៉ាស៊ីនបានរួមចំណែកខ្ពស់បំផុតដល់ផលនេសាទនៅតំបន់ទន្លេសាប ៧៤,១% និង៧១,៩% សម្រាប់តំបន់ខ្ពង់រាប នេះបង្ហាញពីការពឹងផ្អែកកាន់តែខ្លាំងលើកន្លែងនេសាទ ដែលស្ថិតនៅឆ្ងាយពីផ្ទះរបស់អ្នកនេសាទនៅក្នុងតំបន់ទាំងនេះ។ ក៏ប៉ុន្តែ ការនេសាទដោយទូកមានម៉ាស៊ីនបានអនុវត្តជាទូទៅនៅតាមតំបន់នេសាទទាំងអស់ ដែលមាន ៦០,២០% នៃផលនេសាទសរុប ខណៈដែលការនេសាទដោយមិនប្រើប្រាស់ទូកតំណាងឱ្យ ៣០,៩០%។

**តារាងទី៥.** ផលនេសាទ(គ.ក្រ) សម្រាប់ឆ្នាំ២០២៣ ជាមួយសមាមាត្រនេសាទតាមប្រភេទទូកនិងតំបន់នេសាទនីមួយៗ

| តំបន់នេសាទ | ផលនេសាទសរុប (គ.ក្រ) | មិនប្រើទូក(%) | ទូកមានម៉ាស៊ីន(%) | ទូកមិនមានម៉ាស៊ីន(%) |
|---|---|---|---|---|
| ឆ្នេរ | ៦១៦,៧ | ៩២,១ | ២,៣ | ៥,៦ |
| ទំនាបលិចទឹក | ៣.៩៣៣,១ | ៥៣,៥ | ៣០ | ១៦,៥ |
| ខ្ពង់រាប | ៥.៩១២,៩ | ១៦,៥ | ៧១,៩ | ១១,៦ |
| ទន្លេសាប | ១៥.៤៤៣,៦ | ២០,២ | ៧៤,១ | ៥,៦ |
| ភ្នំ | ៣.៤៩៩ | ៦៦,៧ | ២២,៨ | ១០,៥ |
| **សរុប** | **២៩.៤០៥,៣** | **៣០,៩** | **៦០,២** | **៨,៩** |

[2] មិនមានចំនួនអ្នកនេសាទជាក់លាក់ ប៉ុន្តែការប៉ាន់ប្រមាណមួយចំនួនដោយផ្អែកលើការសម្ភាសន៍ជ្រើសរើសគ្រួសារ (HH) ទិន្នន័យនេះនឹងត្រូវបានវាយតម្លៃបន្ថែមទៀតក្នុងកំឡុងឆ្នាំ២០២៣។

[3]លទ្ធផលនេះគឺមិននឹកស្មានដល់ ហើយផ្ទុយទៅនឹងអ្វីដែលយើងរំពឹងទុកជាទូទៅ តែអាចបណ្ដាលមកពីភាពលំអៀងនៅក្នុងសំណាក ដែលអ្នកនេសាទប្រើទូកមានម៉ាស៊ីន មិនត្រូវបានតំណាងឱ្យបានពេញលេញ។

សមាមាត្រសរុបដោយផ្អែកលើទម្ងន់ផលនេសាទជាមធ្យមតាមប្រភេទទូកចម្បងៗ និងតំបន់នេសាទ មិនមែនជាផលនេសាទសរុប[4]។




**ក្រាហ្វិកទី២.** ការរួមចំណែកសរុបនៃប្រភេទទូកសំខាន់ៗ ទៅនឹងផលនេសាទសរុប

ទីជម្រកនេសាទសំខាន់ៗ ដូចមានបង្ហាញក្នុងក្រាហ្វិកទី៣ រួមមានតំបន់ទំនាបលិចទឹក ផ្លូវទឹកនានា(ស្ទឹង) ហូរចូលបឹងទន្លេសាប និងដងទន្លេមេគង្គនិងដៃសំខាន់ៗ។ ជម្រកសំខាន់ៗនៃតំបន់ទំនាបលិចទឹក គឺវាលស្រែរងទឹកភ្លៀង (៤៧,៧%) ហើយបឹងនិងត្រពាំង (៣៣,០%)។ ការរួមចំណែកនៃតំបន់ព្រៃលិចទឹក (៩,៥%) ដែលប្រហែលជាតំបន់ព្រៃលិចទឹកទាំងនេះ គឺច្រើនស្ថិតក្នុងតំបន់ការពារ និងវាលស្រែទឹកជំនន់ (៩,៧%) មានកម្រិតទាប គឺអាចមកពីគ្រួសារនេសាទទំនងជាការលំបាកក្នុងការបែងចែកផ្សេងគ្នារវាងវាលស្រែទឹកជំនន់ និងវាលស្រែរងទឹកភ្លៀង[4]។




**ក្រាហ្វិកទី៣.** ការរួមចំណែកសរុបនៃជម្រកសំខាន់ៗ ទៅនឹងផលនេសាទសរុប រួមនឹងសមាមាត្រនៃផលនេសាទពីជម្រកនៅតាមតំបន់ទំនាបលិចទឹក

[4] លុះត្រាតែអ្នកប្រមូលទិន្នន័យបានបញ្ជាក់ជាក់លាក់ពីភាពខុសគ្នារវាងស្រែស្រោចស្រព និងស្រែរងរបបទឹកភ្លៀង អ្នកឆ្លើយតបសំនួរភាគច្រើនចាត់ទុកប្រភេទជម្រកទាំងពីរនេះជាជម្រកដូចគ្នា

**តារាងទី៦.** សមាមាត្រ និងផលនេសាទតាមទីជម្រក សម្រាប់ផលនេសាទដែលបានមកតែ១ទីជម្រកតាមតំបន់នេសាទ

| ប្រភេទទីជម្រកនេសាទ | តំបន់ឆ្នេរ (%) | តំបន់ទំនាបលិចទឹក(%) | តំបន់ខ្ពង់រាប (%) | តំបន់ទន្លេសាប (%) | តំបន់ភ្នំ(%) | សរុប(%) |
|---|---|---|---|---|---|---|
| ផ្លូវទឹកនានាហូរចូលបឹងទន្លេសាប | | ១១,៧ | | ៥១,៩ | ០,១ | ២៩,៥ |
| ដងទន្លេមេគង្គ | | ១៣,៩ | ៦៦ | | ០,៩ | ១៦,៤ |
| ទំនាបលិចទឹក៖វាលស្រែ (ទឹកភ្លៀង) | ៤៨,៣ | ២៤,១ | ២,៥ | ១៤ | ៣៩,១ | ១៦,៤ |
| ទំនាបលិចទឹក៖ បឹងនិងត្រពាំង | ១៣,៧ | ១៨,៣ | ៣,៥ | ៨,៤ | ៣២,១ | ១៥,៧ |
| ដៃទន្លេសំខាន់ៗ | | ៧ | ៩,៤ | ៣,៤ | ២២,៣ | ១០,៩ |
| អូរ | ០,៨ | ៥,៥ | ១៦,៧ | ១,៩ | ០,៥ | ៥,៥ |
| ស្ទឹង | ១៣ | ១,៣ | | ៥,៦ | ២,៦ | ៣,៧ |
| ទំនាបលិចទឹក៖ វាលស្រែ(ទឹកជំនន់) | ៣,២ | ៤,៣ | ១,៣ | ៤,១ | ០,៤ | ៣,២ |
| ទំនាបលិចទឹក៖ ព្រៃលិចទឹក | | ០,៨ | ០,១ | ៥,៦ | ០,១ | ៣,១ |
| ប្រឡាយធារាសាស្ត្រ | ១៦,៨ | ១០,២ | ០,៣ | ១,៦ | ០,៧ | ២,៦ |
| អាងស្តុកទឹក | ២,៣ | ១,៨ | ០,១ | ២,៧ | | ១,៧ |
| មិនមានបញ្ជាក់ទីជម្រក | ១,៤ | ១ | | ០,៧ | ១,១ | ០,៧ |
| វាលភក់តាមរដូវកាល | ០,៥ | ០,១ | | ០,១ | | ០,១ |
| **សរុប** | **៧៥៥,៩** | **៥.១៩៩,៣** | **៧.៨៣២,៦** | **១៩.៤៤៤** | **៤.៣៩៥,៧** | **៣៧.៦២៧.៥** |

រួមបញ្ចូលផលនេសាទសម្រាប់ថ្ងៃធ្វើនេសាទណា ដែលបាននេសាទពី ១ទីជម្រកប៉ុណ្ណោះ។

ភាពខុសគ្នារវាងតំបន់នេសាទ (តារាងទី៦) បានឆ្លុះបញ្ចាំងពីធម្មជាតិនៃផលផល ក្នុងនោះការនេសាទតាមដងទន្លេមេគង្គមានសារៈសំខាន់បំផុតសម្រាប់គ្រួសារនៅតំបន់ខ្ពង់រាប បន្ទាប់មកគ្រួសារនៅតំបន់ទំនាបលិចទឹក។ វាលស្រែរងទឹកភ្លៀង គឺមានសារៈសំខាន់ដល់គ្រួសារនេសាទនៅគ្រប់តំបន់នេសាទទាំងអស់ ហើយទីជម្រកនេសាទនេះកាន់តែមានសារៈសំខាន់សម្រាប់គ្រួសារនៅតំបន់ភ្នំ និងតំបន់ឆ្នេរ ក៏ប៉ុន្តែបើពិនិត្យជារួមលើការរួមចំណែកនេះ វាលស្រែរងទឹកភ្លៀងមានតួនាទីសំខាន់ខ្លាំងសម្រាប់គ្រួសារនៅតំបន់ទន្លេសាប។ ដៃទន្លេសំខាន់ៗ នៅគ្រប់តំបន់នេសាទលើកលែងតែតំបន់ឆ្នេរក៏មានសារៈសំខាន់ផងដែរ ប៉ុន្តែមានការលំបាក[5] ក្នុងការបែងចែកភាពខុសគ្នារវាងប្រភេទស្ទឹងផ្សេងៗគ្នា ជាពិសេសរវាងស្ទឹងនិងអូរ។

ទីជម្រក មិនមានបញ្ជាក់ទីជម្រក គឺមានបង្ហាញនូវគ្រប់ទីជម្រកទាំងអស់ លើកលែងតែតំបន់ខ្ពង់រាប ប៉ុន្តែកំណត់ត្រាអង្កេតមានតិចតួចបំផុត។

[5]ស្ទឹងគឺជាផ្លូវទឹកតូចភ្ជាប់ទៅដៃទន្លេនិងទន្លេ ដែលមានទឹកជាប្រចាំ ហើយអូរជាផ្លូវទឹកតាមរដូវកាល។

ផលនេសាទប្រចាំថ្ងៃជាមធ្យមនៅតាមទីជម្រកនេសាទ តារាងទី៧ក គឺមានភាពខុសគ្នាខ្លាំងតាមប្រភេទនៃទីជម្រក និងតាមទីជម្រកដូចគ្នានៅតាមតំបន់នេសាទផ្សេងៗគ្នាផងដែរ។ ស្ទើរតែគ្រប់ទីជម្រកទាំងអស់ តំបន់ទន្លេសាបមានផលនេសាទមធ្យមប្រចាំថ្ងៃខ្ពស់ជាងគេបើធៀបនឹងតំបន់ផ្សេងទៀត។ លទ្ធផលអង្កេតនេះ បង្ហាញពីភាពខុសគ្នានៃផលិតភាពជាក់ស្តែងតាមតំបន់ និងភាពខុសគ្នានៃការប្រើប្រាស់ឧបករណ៍ដូចជាបរិមាណ ឬទំហំ។

តម្លៃដែលមានភាពត្រឹមត្រូវតាមបែបស្ថិតិទាប គឺតម្លៃនៃលំអៀងស្តង់ដារប្រៀបធៀប (ε%) ខ្ពស់ជាង ៣០% ដែលបានបង្ហាញជាអក្សរពណ៌ក្រហមចាស់ជាមួយនឹងផ្ទៃខាងក្រោយពណ៌ទឹកក្រូចស្រាល។ តម្លៃទាំងនេះ មិនអាចប្រើតំណាងតម្លៃពិតបានទេ ដោយសារភាពប្រែប្រួលទិន្នន័យខ្ពស់ និងដោយសារចំនួនការសង្កេតទាបពេក។ ជាការកត់សម្គាល់សម្រាប់ជម្រកមិនមានបញ្ជាក់ជាក់លាក់ ដែលតម្លៃ CPUE ជាមធ្យមស្ទើរតែទាំងអស់ខ្វះភាពត្រឹមត្រូវតាមន័យស្ថិតិ លើកលែងតែតំបន់ទំនាបលិចទឹកប៉ុណ្ណោះ។ កត្តានេះបណ្តាលមកពីទីជម្រកមិនមានបញ្ជាក់ជាក់លាក់មានរួមបញ្ចូលទីជម្រកច្រើនជាងមួយ ជាមួយនឹងលក្ខណៈនេសាទចម្រុះខ្លាំង។

សារៈសំខាន់នៃផលនេសាទប្រចាំថ្ងៃ គឺផ្តល់នូវចំណុចប្រៀបធៀបមួយរវាងឆ្នាំផ្សេងគ្នា ដើម្បីវាយតម្លៃថាតើផលនេសាទក្នុងឆ្នាំផ្សេងទៀតមានតម្លៃខុសគ្នា ជាជំនួយក្នុងការប៉ាន់ប្រមាណទិន្នផលសរុបដោយផ្អែកលើផលនេសាទមធ្យមតាមគ្រួសារ និងសម្រាប់វាយតម្លៃពីសារៈសំខាន់នៃជម្រកនេសាទសំខាន់ៗលើផលិតភាពសរុបតាមតំបន់នេសាទផ្សេងៗគ្នា។

**តារាងទី៧ក.** ផលនេសាទមធ្យមតាមគ្រួសារប្រចាំថ្ងៃ (គ.ក្រ/ថ្ងៃ) តាមជម្រកនេសាទ និងតំបន់នេសាទនីមួយៗ

| ជម្រកនេសាទ | តំបន់ឆ្នេរ | ទំនាបលិចទឹក | តំបន់ខ្ពង់រាប | ទន្លេសាប | តំបន់ភ្នំ | សរុប |
|---|---|---|---|---|---|---|
| ផ្លូវទឹកនានាហូរចូលបឹងទន្លេសាប | | ៣,២ | | ១០,១ | **១,៦** | ៩,១ |
| ទំនាបលិចទឹក:ព្រៃលិចទឹក | | ២,៧ | ២ | ១០,១ | ១,៣ | ៨,៩ |
| ដៃទន្លេសំខាន់ៗ | | ៣,៩ | ៨,៣ | ១១,៩ | ៧,៧ | ៧,៦ |
| ទីជម្រកមិនមានបញ្ជាក់ជាក់លាក់ | **២** | ២ | | **៨,៦** | **៣៤,៥** | **៥,៣** |
| ដងទន្លេមេគង្គ | | ៣,៨ | ៥,៥ | ០,៧ | ៤,៦ | ៥,២ |
| ទំនាបលិចទឹក:វាលស្រែ(ទឹកជំនន់) | ៦,៣ | ២,៩ | ២,៦ | ៥,៩ | **១,៩** | ៤,៥ |
| អាងស្តុកទឹក | ១,៥ | ៣,២ | ២,៧ | ៤,២ | | ៣,៩ |
| វាលភក់អចិន្ត្រៃយ៍ | | ១,៤ | | ៩.២ | | **៣,៦** |
| ទំនាបលិចទឹក:វាលស្រែ(ទឹកភ្លៀង) | ៣,៥ | ២,៨ | ២,៣ | ៤,៥ | ៣,២ | ៣,៦ |
| ទំនាបលិចទឹក:បឹងនិងត្រពាំង | ២,៥ | ៣,៣ | ២,៣ | ៣,៨ | ៣,៩ | ៣,៥ |
| ស្ទឹង | ១,៩ | **៤,៦** | | ៣,១ | ៤,៤ | ៣,១ |
| អូរ | ១ | ២,២ | ៣,៣ | ១,៦ | ៥,៣ | ២,៦ |
| ប្រឡាយធារាសាស្ត្រ | ១,៨ | ១,៩ | ១,៩ | ១,៧ | ២,២ | ១,៨ |
| វាលភក់តាមរដូវកាល | **២,៨** | **១,១** | | ១,២ | | ១,៣ |

**តារាងទី៧ខ.** សមាមាត្រនៃថ្ងៃធ្វើនេសាទតាមទីជម្រក តាមតំបន់នេសាទ

| **ជម្រកនេសាទ** | **តំបន់ឆ្នេរ** | **ទំនាបលិចទឹក** | **តំបន់ខ្ពង់រាប** | **ទន្លេសាប** | **តំបន់ភ្នំ** | **សរុប** |
|---|---|---|---|---|---|---|
| ផ្លូវទឹកនានាហូរចូលបឹងទន្លេសាប | - | ១០,៧% | - | ៣០,៧% | ០,១% | ១៥,៣% |
| ទំនាបលិចទឹក:ព្រៃលិចទឹក | - | ០,៨% | ០,២% | ៣,៣% | ០,៤% | ១,៧% |
| ដៃទន្លេសំខាន់ៗ | - | ៥,២% | ៥,៣% | ១,៧% | ១១,៦% | ៤,៣% |
| ទីជម្រកមិនមានបញ្ជាក់ជាក់លាក់ | ១,៧% | ១,៤% | - | ០,៥% | ០,១% | ០,៦% |
| ដងទន្លេមេគង្គ | - | ១០,៧% | ៥៥,៥% | ០,១% | ០,៨% | ១៤,៨% |
| ទំនាបលិចទឹក:វាលស្រែ(ទឹកជំនន់) | ១,៣% | ៤,៣% | ២,៤% | ៤,២% | ០,៩% | ៣,៤% |
| អាងស្តុកទឹក | ៣,៩% | ១,៦% | ០,២% | ៣,៨% | - | ២,១% |
| វាលភក់អចិន្ត្រៃយ៍ | - | ០,៣% | - | ០,១% | - | ០,១% |
| ទំនាបលិចទឹក:វាលស្រែ(ទឹកភ្លៀង) | ៣៥,៧% | ២៤,៩% | ៥% | ១៨,៦% | ៤៩,១% | ២០,៧% |
| ទំនាបលិចទឹក:បឹងនិងត្រពាំង | ១៣,៩% | ១៦,២% | ៧% | ១៣,១% | ៣២,៩% | ១៤,៦% |
| ស្ទឹង | ១៧,៤% | ០,៨% | **0,0%** | ១០,៨% | ២,៤% | ៥,៦% |
| អូរ | ២,២% | ៧,២% | ២៣,៧% | ៧,៣% | ០,៤% | ១០% |
| ប្រឡាយធារាសាស្ត្រ | ២៣,៥% | ១៥,៤% | ០,៨% | ៥,៥% | ១,៣% | ៦,៦% |
| វាលភក់តាមរដូវកាល | ០,៤% | ០,៣% | - | ០,៣% | - | ០,២% |

ទន្ទឹមនឹងនេះ សមាមាត្រនៃសមត្ថភាពចាប់សម្រាប់ទីជម្រកនេសាទតាមតំបន់នេសាទ (តារាងទី៧ខ) ផ្តល់នូវព័ត៌មានលម្អិតអំពីចំនួនមធ្យមនៃគ្រួសារទៅនេសាទ និងថ្ងៃធ្វើនេសាទជាមធ្យម។

ឧបករណ៍នេសាទសំខាន់បំផុត ដោយផ្អែកលើការរួមចំណែកតាមឧបករណ៍ទាំងនោះទៅនឹងផលនេសាទ (ក្រាហ្វិកទី៤) គឺមងកាំង (៣៤,៧%) លប (១៨,៧%) មងបណ្តែត (១១,៤%) អួន (៣,៩%) និងសំណាញ់ (៤,៤%)។ ភាពខុសគ្នានៅក្នុងការរួមចំណែកតាមឧបករណ៍នេសាទ ឧ. ការប្រើសំណាញ់មានការថយចុះចាប់ពីឆ្នាំ២០២២ទំនងជាដោយសារតែទិន្នន័យឆ្នាំ២០២៣ មិនបានគ្របដណ្តប់នៅអំឡុងពេលរដូវប្រាំង។ ឧបករណ៍ដែលមិនបានបញ្ជាក់ជាក់លាក់បានរួមចំណែក ៦,៨% នៃផលនេសាទសរុប។




**ក្រាហ្វិកទី៤.** ការរួមចំណែកនៃឧបករណ៍នេសាទទៅផលនេសាទប៉ាន់ប្រមាណសរុប

ស្រដៀងគ្នាទៅនឹងសារៈសំខាន់នៃទីជម្រកផ្សេងៗគ្នា សារៈសំខាន់នៃការរួមចំណែកនៃឧបករណ៍នេសាទទៅនឹងផលនេសាទដែលបានរាយការណ៍ ភាគច្រើនបង្ហាញពីលក្ខណៈផ្សេងៗគ្នានៃតំបន់នេសាទ (តារាងទី៨)។ មងកាំងមានសារៈសំខាន់បំផុត (ប្រើច្រើន) សម្រាប់តំបន់ខ្ពស់រាប ហើយមងបណ្តែតមានសារៈសំខាន់ជាងគេសម្រាប់តំបន់ទំនាបលិចទឹក។ លបជាឧបករណ៍នេសាទមានសារៈសំខាន់នៅតាមតំបន់នេសាទទាំងអស់ ប៉ុន្តែបានរួមចំណែកខ្ពស់ជាងគេដល់ផលនេសាទនៅតំបន់ទន្លេសាបនិងតំបន់ឆ្នេរ ដោយលបតូចសំខាន់ខ្លាំង (ប្រើប្រាស់) ជាងលបធំ។ ឧបករណ៍ផ្សេងៗទៀត ដែលមិនមានបញ្ជាក់ប្រភេទឧបករណ៍ ត្រូវបានរកឃើញនៅតាមតំបន់នេសាទទាំងអស់ និងបានរួមចំណែក ៩,៤% នៃផលនេសាទសរុប ប៉ុន្តែការរួមចំណែកដល់ផលនេសាទគឺមានជាទូទៅសម្រាប់តំបន់ភ្នំ។

**តារាងទី៨.** សមាមាត្រនៃផលនេសាទតាមឧបករណ៍ និងតំបន់នេសាទ សម្រាប់ថ្ងៃនេសាទប្រើ១ឧបករណ៍

| ឧបករណ៍នេសាទ | តំបន់ឆ្នេរ | ទំនាបលិចទឹក | តំបន់ខ្ពង់រាប | ទន្លេសាប | តំបន់ភ្នំ | សរុប |
|---|---|---|---|---|---|---|
| មងកាំង | ៣៤,៤% | ២១,៨% | ៧១,៩% | ២៧,៩% | ១៧,៥% | ៣៤,៧% |
| លប (តូច) | ១៧,២% | ១១,១% | ៦,៣% | ២៦,២% | ១០,៥% | ១៨,៧% |
| មងបណ្តែត | ១០,២% | ២៩,៩% | ១០,១% | ៨,៦% | ១,៥% | ១១,៤% |
| ឧបករណ៍មិនមានបញ្ជាក់ | ២,៨% | ១,៨% | ៣,៤% | ១០,១% | ៣៤% | ៩,៤% |
| សំណាញ់ | ៣,៩% | ៨,១% | ១,៦% | ៣,៤% | ១១,៥% | ៤,៤% |
| អួន | ០,០% | ២% | ០,០% | ៦,៤% | ០,៤% | ៣,៩% |
| ចាប់ដោយដៃ | ២០,៣% | ៤,៦% | ០,២% | ៤,២% | ៤,១% | ៣,៨% |
| សន្ទូចបង្កៃ/បង្កង/វាត់ | ១,៣% | ៣% | ៣,៤% | ២,៥% | ២,៤% | ២,៧% |
| លប (ធំ) | ០,៣% | ១,៣% | ០,៦% | ៣,៣% | ៣,៣% | ២,៤% |
| សន្ទូច | ០,៥% | ១,៣% | ០,៥% | ៣,៥% | ០,០% | ២,៣% |
| ថ្នង | ០,០% | ០,១% | ០,០% | ២,៦% | ០,០% | ១,៤% |
| សៃយ៉ឺន | ២,៥% | ៦,១% | ០,០% | ០,២% | ២,៦% | ១,៣% |
| ស្នូ/សម/ច្បូក | ៣,២% | ៥% | ០,០% | ០,៣% | ០,៣% | ១% |
| សន្ទូចរាយ | ០,០% | ១,២% | ២% | ០,៧% | ០,៥% | ១% |
| ធ្នុក | ០,០% | ០,១% | ០,០% | ០,០% | ១០,៨% | ០,៩% |
| មូប | ០,០% | ១,១% | ០,០% | ០,០% | ០,០% | ០,២% |
| ឈិប | ២,៥% | ០,០% | ០,០% | 0.1% | ០,២% | ០,២% |
| អួនអូសគូ | ០,៥% | ០,៨% | ០,០% | ០,០% | ០,០% | ០,១% |
| សំណាញ់ | ០,២% | ០,៥% | ០,០% | ០,០% | ០,០% | ០,១% |
| ឈ្នាង | ០,០% | ០,១% | ០,០% | ០,០% | ០,០% | ០,០៣% |
| ដាយ | ០,០% | ០,១% | ០,០% | ០,០% | ០,០% | ០,០២% |
| ស្នា និងកាំភ្លើង | 0.3% | ០,០% | ០,០% | ០,០% | ០,១% | ០,០២% |

| ឧបករណ៍នេសាទ | តំបន់ឆ្នេរ | ទំនាបលិចទឹក | តំបន់ខ្ពង់រាប | ទន្លេសាប | តំបន់ភ្នំ | សរុប |
|---|---|---|---|---|---|---|
| អង្រុត | 0,0% | 0,0% | 0,0% | 0,0% | 0,២% | 0,0២% |
| ប៉ោង | 0,0% | 0,0% | 0,១% | 0,0% | 0.0% | 0,0១% |
| ឈ្នក់ | 0,0% | 0,0% | 0,0% | 0,0% | 0,១% | 0,0១% |
| ចាន់ | 0,0% | 0,0% | 0,0% | 0,0% | 0,0% | 0,00៣% |
| **ផលនេសាទចាប់ដោយ ១ឧបករណ៍** | **៥៨៦,៦** | **៣.៩៦៣,៣** | **៥.២០៨,៤** | **១៥.១១៩,៦** | **២.២៦២,១** | **២៧.១៤០** |

តារាងទី៧ រួមបញ្ចូលតែផលនេសាទ ដែលបានធ្វើនេសាទដោយប្រើ ០១ឧបករណ៍ ដូច្នេះផលនេសាទសរុប គឺខុសពីផលនេសាទតាមទីជម្រកនីមួយៗ។ ដូចបង្ហាញក្នុងតារាងទី៩ ជារួម ២៧,៩%នៃផលនេសាទ គឺបានមកពីការនេសាទដោយប្រើឧបករណ៍ច្រើនក្នុងមួយថ្ងៃនេសាទ។ សមាមាត្រនៃផលនេសាទសម្រាប់ថ្ងៃនេសាទប្រើឧបករណ៍ច្រើន គឺខ្ពស់បំផុតសម្រាប់គ្រួសារនៅតំបន់ភ្នំ(៤៨,៥%) បន្ទាប់មកតំបន់ខ្ពង់រាប(៣៣,៥%)។

**តារាងទី៩.** សមាមាត្រនៃផលនេសាទពីថ្ងៃធ្វើនេសាទដោយប្រើឧបករណ៍ច្រើនប្រភេទ

| ឧបករណ៍នេសាទ | តំបន់ឆ្នេរ | ទំនាបលិចទឹក | តំបន់ខ្ពង់រាប | ទន្លេសាប | តំបន់ភ្នំ | សរុប |
|---|---|---|---|---|---|---|
| ឧបករណ៍ច្រើនប្រភេទ | ២២,៤% | ២៣,៨% | ៣៣,៥% | ២២,២% | ៤៨,៥% | ២៧,៩% |
| **ផលនេសាទរបានពីពហុឧបករណ៍** | **១៦៩,៣** | **១.២៣៦** | **២.៦២៤,២** | **៤.៣២៤,៤** | **២.១៣៣,៦** | **១០.៤៨៧,៥** |

ការប្រើប្រាស់ចំនួនថ្ងៃនេសាទ ជំនួសឱ្យផលនេសាទ ធ្វើឱ្យមានភាពខុសប្លែកគ្នាមួយចំនួនសម្រាប់សារៈសំខាន់នៃឧបករណ៍នេសាទ។ ឧបករណ៍នេសាទដែលមាន CPUE ខ្ពស់ជាងគេ ដូចជាអួន អាចមានភាគរយខ្ពស់នៃផលនេសាទ ប៉ុន្តែសមាមាត្រនៃសមត្ថភាពចាប់ទាបជាង។




**ក្រាហ្វិកទី៥.** ការរួមចំណែកនៃសមត្ថភាពចាប់ប្រចាំខែ (ថ្ងៃនេសាទ) សម្រាប់ប្រភេទឧបករណ៍ដែលគេនិយមប្រើប្រាស់ទាំង៥ តាមខែ និងចំនួនថ្ងៃនេសាទសរុប

**តារាងទី១០.** ផលនេសាទជាមធ្យមប្រចាំថ្ងៃ (គ.ក្រ) តាមឧបករណ៍និងតំបន់នេសាទ និងសមត្ថភាពចាប់សរុប(ថ្ងៃ)

| ឧបករណ៍នេសាទ | តំបន់ឆ្នេរ | ទំនាបលិចទឹក | តំបន់ខ្ពង់រាប | ទន្លេសាប | តំបន់ភ្នំ | សរុប | សមត្ថភាពចាប់ |
|---|---|---|---|---|---|---|---|
| មងកាំង | **៣,៧** | ៣,៣ | ២,៧ | ៧,៥ | ៥,៧ | ៥,៥ | ១៧០១ |
| លប (តូច) | ២,៣ | ៣,២ | ៩,៩ | ៣,៨ | ៦,៥ | ៥,៦ | ៩០៨ |
| មងបណ្តែត | ១,៨ | ៣,៤ | ៣,៧ | ៣,៨ | ៧,១ | ៤,៣ | ៧១៥ |
| សំណាញ់ | ១,៥ | ២,២ | ២,៧ | ២,១ | ២,០ | ២,២ | ៥៥៣ |
| មិនមានបញ្ជាក់ជាក់លាក់ | **២,៣** | ១,៩ | ៥,៧ | ៣,៩ | ៨,៨ | ៦,៤ | ៣៩៧ |
| សន្ទូចបង្កៃ/បង្កង/វ៉ាត់ | ៣,៨ | ២,៣ | ១,៦ | ១,៦ | ២,៨ | ២,២ | ៣៣៤ |
| ចាប់ដោយដៃ | ២,៦ | ២,៦ | ១,៨ | ៣,០ | ៤,៦ | ៣,៤ | ៣០៥ |
| សៃយ៉ឺន | ១,៧ | ២,២ | ២,៩ | | ១,៩ | ២,២ | ១៥៧ |
| សន្ទូច | | ២,៥ | ០,៧ | ១,១ | ៣,១ | ១,៧ | ១៦២ |
| លប (ធំ) | ១,០ | ៣,៨ | ៣,៣ | ៣,៦ | ៥,៨ | ៤,៩ | ១៣៣ |
| សន្ទូចរាយ | ២,៨ | ៣,០ | | ១,១ | ៦,៥ | ៥,០ | ១២២ |
| ស្នរ | ៣,២ | ២,០ | ១,៤ | | **៤,៥** | ២,២ | ១២៣ |
| អួន | | **៣,៦** | ១,៦ | | ២៨,៦ | ១៧,៤ | ៦១ |
| ឈិប | ១,៩ | | ០,៩ | ០,៥ | ២,៣ | ១,៧ | ២៦ |
| ធ្នក | | ៣,០ | ៩,៨ | | | ៩,៥ | ២៦ |
| ថ្នង | | ២,៦ | | | ២៤,១ | ២២,៩ | ១៧ |
| អួនអុសគូ | ២,៨ | ៤,៥ | | | | ៤,៣ | ៨ |
| ប៉ោង | | | | ០,៥ | | ០,៥ | ៦ |
| ឈ្នាង | | ១,៨ | | | **០,៥** | ១,១ | ៦ |
| សំណាញ់ធំ | ១,០ | ៥,៣ | | | | ៤,៤ | ៥ |
| ជាយ | | **១,៨** | | | | **១,៨** | ៣ |
| បូម | | ២១,៥ | | | **០,៧** | **១១,១** | ៤ |
| ស្នានិងកាំភ្លើង | ១,៥ | | ១,៤ | | | ១,៤ | ៣ |
| អង្រុត | | | ១,៤ | | | ១,៤ | ៣ |
| ចាន់ | | | | ០,៤ | | ០,៤ | ២ |
| ឈ្នក់ | | | ២,៩ | | | ២,៩ | ១ |

ឧបករណ៍នេសាទមួយចំនួន គឺត្រូវបានប្រើប្រាស់ខុសគ្នាទៅតាមរដូវកាល (ក្រាហ្វិកទី៥)។ ការប្រើប្រាស់សន្ទូចបង្កៃស្ទើរតែពុំមាននៅរដូវទឹកជំនន់ ខណៈដែលលបបានប្រើច្រើនជាងខ្លាំងក្នុងអំឡុងពេលទឹកជំនន់។ ឧបករណ៍សំណាញ់ត្រូវបានប្រើប្រាស់ពេញមួយឆ្នាំ ហើយឧបករណ៍នេះសកម្មខ្លាំងបំផុតនៅដើមក្នុងរដូវប្រាំង។ ជាការកត់សម្គាល់ ទិន្នន័យសម្រាប់ខែធ្នូ តំណាងឱ្យតែភូមិតំបន់ភ្នំចំនួន៣ និងភូមិតំបន់ទន្លេសាបចំនួន៥ ប៉ុណ្ណោះ ដូច្នេះលទ្ធផលអង្កេតនេះមិនអាចតំណាងដល់ជលផលទាំងមូលបានទេ។

ទិន្នន័យដែលមាន អាចធ្វើការគណនាផលនេសាទជាមធ្យមប្រចាំថ្ងៃតាមឧបករណ៍នេសាទ ឬ CPUE ដែលបង្ហាញក្នុងតារាងទី១០ ក៏ដូចជាចំនួនថ្ងៃនេសាទសរុប ដែលមានផលនេសាទធំជាងសូន្យ។ ឧបករណ៍នេសាទនៅក្នុងតារាងត្រូវបានតម្រៀបដោយផ្អែកលើសមត្ថភាពចាប់សរុប ជាមួយនឹងតម្លៃទាំងអស់សម្រាប់ CPUE។ សម្រាប់ការវាយតម្លៃពីភាពជាក់លាក់នៃស្ថិតិ ផ្ទៃខាងក្រោយពណ៌ទឹកក្រូច និងពុម្ពអក្សរពណ៌ក្រហមបង្ហាញពីតម្លៃ ៩% ខ្ពស់ជាង៣០%។ មានករណីលើកលែងមួយចំនួន ដូចជាលបតូចសម្រាប់គ្រួសារតំបន់ភ្នំជាដើម ឧបករណ៍នេះភាគច្រើនមាន CPUE មធ្យមខ្ពស់បំផុតសម្រាប់គ្រួសារនៅតំបន់ខ្ពង់រាប ឬតំបន់ទន្លេសាប។ ភាពខុសគ្នារវាងឧបករណ៍សម្រាប់តំបន់នេសាទដូចគ្នា គឺមានទំហំតូច។ មង គឺជាឧបករណ៍នៅមួយកន្លែងក្នុងការនេសាទត្រី ហើយជាឧបករណ៍ដ៏សំខាន់បំផុតមួយទាំងនៅក្នុងការនេសាទ និង CPUE។

ដូចបានបង្ហាញតារាងទី១១ ការលក់ត្រីមានសារៈសំខាន់បំផុតសម្រាប់តំបន់ទំនាបលិចទឹក មានចំនួន៤៦,១% និងតំបន់ទន្លេសាប៧២,០% នៃផលនេសាទ។ នៅតំបន់នេសាទភាគច្រើន ផលនេសាទច្រើនជាង ៣៥% ត្រូវបានប្រើប្រាស់ក្នុងគ្រួសារ លើកលែងតែតំបន់ទន្លេសាប ដែលមានត្រឹមតែ ១៦,៩% ប៉ុណ្ណោះ។ ការប្រើប្រាស់ផលនេសាទតាមគ្រួសារភាគច្រើន គឺបរិភោគត្រី និង សត្វវារីសត្វស្រស់ (OAA)។ ផលនេសាទផ្សេងទៀត ត្រូវបានប្រើប្រាស់ជាចម្បងសម្រាប់ការកែច្នៃ និងប្រើប្រាស់នៅក្នុងវារីវប្បកម្ម (ចញ្ចឹមក្រពើ)។ ការប្រើប្រាស់ផលនេសាទ គឺខ្ពស់ជាងគេនៅតំបន់ខ្ពង់រាប និងតំបន់ឆ្នេរ ខណៈដែលការប្រើប្រាស់មានទាបបំផុតនៅតំបន់ទន្លេសាប និងតំបន់ទំនាបលិចទឹក ដែលជាកន្លែងដែលអាចរកត្រីបានពេញមួយឆ្នាំ។

**តារាងទី១១.** ការប្រើប្រាស់ផលនេសាទតាមតំបន់នេសាទ គិតជាទម្ងន់និងសមាមាត្រ

| តំបន់នេសាទ | លក់ (គ.ក្រ) | %លក់ | បរិភោគ (គ.ក្រ) | (%) បរិភោគ | ផ្សេងទៀត (គ .ក្រ) | %ផ្សេងទៀត |
|---|---|---|---|---|---|---|
| ឆ្នេរ | ២៤៨,៨ | ៣២,៩% | ៣០២,៨ | ៤០,១% | ២០៤,៣ | ២៧,០% |
| ទំនាបលិចទឹក | ២.៣៩៨ | ៤៦,១% | ១.៨០៨,១ | ៣៤,៨% | ៩៩៣,២ | ១៩,១% |
| ខ្ពង់រាប | ២.៥៨៤,៦ | ៣៣,០% | ២.៧៣៨,៣ | ៣៥,០% | ២.៥០៩,៧ | ៣២,០% |
| ទន្លេសាប | ១៣.៩៩៨,៤ | ៧២,០% | ៣.២៨៥,៨ | ១៦,៩% | ២.១៥៩,៨ | ១១,១% |
| ភ្នំ | ១.៦៦៦,៧ | ៣៧,៩% | ១.៦២៥,៦ | ៣៧,០% | ១.១០៣,៥ | ២៥,១% |
| **សរុប** | **២០.៨៩៦,៥** | **៥៥,៥%** | **៩.៧៦០,៦** | **២៥,៩%** | **៦.៩៧០,៤** | **១៨,៥%** |




**ក្រាហ្វិកទី៦.** ការប្រើប្រាស់ផលនេសាទសម្រាប់ឆ្នាំ២០២៣ តាមផ្នែកសំខាន់ៗ ដោយដាក់តំបន់នេសាទទាំងអស់រួមបញ្ចូលគ្នា

ការប្រើប្រាស់ផលនេសាទដោយដាក់តំបន់នេសាទទាំងអស់រួមបញ្ចូលគ្នា (ក្រាហ្វិកទី៦) បានបង្ហាញថា ផលនេសាទភាគច្រើនត្រូវបានលក់។ លទ្ធផលនេះ តំបន់ទន្លេសាប ដែលមានចំនួនត្រីលក់ខ្ពស់ជាងគេបំផុត រហូតដល់ប្រមាណជាង៥០% នៃផលនេសាទសរុប។ ដើម្បីយល់កាន់តែច្បាស់អំពីការប្រែប្រួលនៃសមាមាត្រត្រីដែលបានលក់ ក្នុងចំណោមតំបន់នេសាទផ្សេងៗគ្នា និងក្នុងរយៈពេលពេញមួយឆ្នាំ ការវិភាគទិន្នន័យគួរតែបែងចែកតំបន់នេសាទតាមខែ។




**ក្រាហ្វិកទី៧.** សមាមាត្ររួមប្រចាំខែនៃផលនេសាទ ដែលបានលក់ តាមតំបន់នេសាទ

ក្រាហ្វិកទី៧ បង្ហាញថា ការលក់ផលនេសាទជាទូទៅកើតមានខ្លាំងនៅដើមរដូវវស្សា។ យ៉ាងណាមិញ ចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា សមាមាត្រនៃការលក់ផលនេសាទមានកម្រិតថេរ ប្រហាក់ប្រហែលគ្នានៅតាមតំបន់នេសាទភាគច្រើន។ តំបន់ទន្លេសាបមានសមាមាត្រនៃការលក់ផលនេសាទខ្ពស់បំផុត ខណៈតំបន់ខ្ពង់រាបមានកម្រិតទាបបំផុត។ ជាការកត់សម្គាល់ផងដែរ ការផ្គត់ផ្គង់ត្រីសម្រាប់តំបន់ខ្ពង់រាបក្នុងខែតុលា គឺស្ថិតខ្ពស់ជាងគេ។




**ក្រាហ្វិកទី៨.** ការរួមចំណែកនៃត្រីនិងវារីសត្វដ៏ទៃទៀត ដល់ផលនេសាទសរុបសម្រាប់នៅក្នុងឆ្នាំ២០២៣

ដោយផ្អែកលើទិន្នន័យដែលបង្ហាញក្នុងក្រាហ្វិកទី៧ ត្រីមានច្រើនលើសលប់នៃផលនេសាទ៨០,៥% ខណៈដែលវារីសត្វផ្សេងៗទៀត (OAA) រួមចំណែក ១៧,៩%។ ក្រាហ្វិកទី៩ បង្ហាញពីការប្រែប្រួលតាមខែ ការប្រែប្រួលនេះជាចម្បងដោយសារតែការកើនឡើងនៃការនេសាទ OAA នៅរដូវវស្សា នៅពេលដែលសមាមាត្រ OAA នៃផលនេសាទនតម្លៃខ្ពស់ជាង។ ជាការកត់សម្គាល់ ទិន្នន័យសម្រាប់ឆ្នាំ២០២៣ មិនមានគ្របដណ្តប់សម្រាប់រដូវប្រាំងទេ (លើកលែងតែភូមិមួយចំនួនក្នុងខែធ្នូ) ការរកឃើញនេះស្របទៅនឹងការស្រាវជ្រាវពីមុន ដែលធ្វើឡើងដោយ IFReDI ដោយផ្អែកលើការសិក្សាអំពីការប្រើប្រាស់ផលនេសាទ បានបង្ហាញថា ជាមធ្យម OAA តំណាងឱ្យ តិចជាង ១០% នៃទិន្នផលនេសាទទឹកសាបសរុប ។




**ក្រាហ្វិកទី៩.** ផលនេសាទត្រីនិងវារីសត្វដទៃទៀត (គ.ក្រ) តាមខែនីមួយៗ

ប្រភេទ ផលនេសាទខ្ពស់ជាងគេទាំង២០ប្រភេទ បានបង្ហាញក្នុង**តារាងទី១២** ដូចខាងក្រោម:

- ក្រុមប្រភេទ(រួមទាំង sp. និងប្រភេទ/ក្រុម nei[6]) តំណាងឱ្យ ២៤,០% នៃផលនេសាទសរុប
- ប្រភេទមិនមែនជាត្រីស្ថិតក្នុងប្រភេទកំពូលគេទាំង២០ គឺក្តាមស្រែ (*Somanniathelphusa sp.*) ត្រីល្អិតចម្រុះ កំពីសចម្រុះ វារីសត្វល្អិត និងខ្យង *(Pomacea canaliculate)*
- សរុបចំនួន ១៣៩ប្រភេទ និងក្រុមប្រភេទទាំងនោះ ត្រូវបានរួមបញ្ចូលនៅក្នុងទិន្នន័យ។ ប្រភេទផលចាប់ដែលខ្ពស់ជាងគេ ២០ប្រភេទ បានតំណាងឱ្យស្មើរតែ ៧៥% នៃផលនេសាទសរុប[7]។

**តារាងទី១២.** ទម្ងន់ សមាមាត្រនៃផលនេសាទ ប្រភេទនិងក្រុមប្រភេទផលនេសាទនៃប្រភេទផលចាប់ខ្ពស់ជាងគេទាំង២០ប្រភេទ សម្រាប់ឆ្នាំ២០២៣

| | **ឈ្មោះវិទ្យាសាស្ត្រ** | **ឈ្មោះភាសាខ្មែរ** | **ផលនេសាទ (គ.ក្រ)** | **ការរួមចំណែកនៃផលនេសាទ** | |
|---|---|---|---|---|---|
| | | | | **សមាមាត្រ** | **បូកយោង** |
| ១ | *Puntioplites proctozysron* | ត្រីច្រកែង | ៤.២៨៦,៤ | ១១,៤% | ១១,៤% |
| ២ | *Somanniathelphusa sp.* | ក្តាមស្រែ | ៣.១៣៤,១ | ៨,៣% | ១៩,៧% |

[6] nei: គ្មានក្នុងក្រុមដទៃ (not elsewhere included)

[7] ប្រភេទ ដែលស្ថិតក្នុងអំបូរត្រីរៀល ( Henicorhynchus sp. ) នៅពេលដាក់ប្រភេទទាំងអស់បញ្ចូលគ្នាធ្វើអោយក្រុមប្រភេទត្រីរៀល លំដាប់ទី៤ ឬប្រហែល ៧% នៃផលនេសាទសរុប។

| | | | | | |
|---|---|---|---|---|---|
| ៣ | *Mixed small or juvenile fish* | ត្រីល្អិតចម្រុះ | ២.៧៤៧ | ៧,៣% | ២៧,0% |
| ៤ | *Channa striata* | ត្រីរ៉ស់/ផ្ទក់ | ២.៤០៤,៣ | ៦,៤% | ៣៣,៤% |
| ៥ | *Henicorhynchus siamensis* | ត្រីរៀលគុប | ២.០៨៩,៥ | ៥,៦% | ៣៩,0% |
| ៦ | *Anabas testudineus* | ត្រីក្រាញ់ | ១.៧៧៨,៧ | ៤,៧% | ៤៣,៧% |
| ៧ | *Henicorhynchus lobatus* | ត្រីរៀលអង្កាម | ១.៥៩៨,៦ | ៤,២% | ៤៧,៩% |
| ៨ | *Hypsibarbus malcolmi* | ត្រីឆ្ពិនមូល | ១.៣៦១ | ៣,៦% | ៥១,៦% |
| ៩ | *Barbonymus gonionotus* | ត្រីឆ្ពិនប្រាក់ | ៩២៤,៣ | ២,៥% | ៥៤,0% |
| ១០ | *Hemibagrus spilopterus* | ត្រីឆ្លាំង | ៨៦២,៦ | ២,៣% | ៥៦,៣% |
| ១១ | *Small mixed shrimps* | កំពឹសចម្រុះ | ៨៦១,៨ | ២,៣% | ៥៨,៦% |
| ១២ | *Mystus singaringan* | ត្រីកញ្ចុះបាយស | ៧៤០,៤ | ២,0% | ៦០,៦% |
| ១៣ | *Aquatic insects nei* | វារីសត្វល្អិត គ្មានក្នុងក្រុមដទៃ | ៧៣៨,៨ | ២,0% | ៦២,៥% |
| ១៤ | *Mystus mysticetus* | ត្រីកញ្ចុះឆ្នូត | ៧៣៤,៩ | ២,0% | ៦៤,៥% |
| ១៥ | *Notopterus notopterus* | ត្រីស្លាត | ៦៩១,៣ | ១,៨% | ៦៦,៣% |
| ១៦ | *Trichopodus trichopterus* | ត្រីកំភ្លាញស្រែ | ៦៥៨,៤ | ១,៧% | ៦៨,១% |
| ១៧ | *Labiobarbus siamensis* | ត្រីអាចម៍កុក | ៦៤៨,២ | ១,៧% | ៦៩,៨% |
| ១៨ | *Osteochilus lini* | ត្រីក្រុស | ៦៤៥,២ | ១,៧% | ៧១,៥% |
| ១៩ | *Cyclocheilichthys enoplos* | ត្រីឆ្ក | ៦៤០,៩ | ១,៧% | ៧៣,២% |
| ២០ | *Pomacea canaliculata* | ខ្យង | ៦១០,៣ | ១,៦% | ៧៤,៨% |
| Other | | ផ្សេងទៀត | ៩.៤៧០,២៨ | ២៥,២% | |
| **ផលនេសាទសរុប** | | | **៣៧.៦២៦,៨** | | |

ភាពចម្រុះនៃប្រភេទ និងការរួមចំណែកទាបនៃក្រុមប្រភេទទាំងនោះនៅក្នុងផលនេសាទ បានផ្តល់នូវទំនុកចិត្តលើផលនេសាទ ដែលត្រូវបានកំណត់ដោយឈ្មោះប្រភេទជាភាសាខ្មែរតាម។ ដោយឡែក ក្រុមប្រភេទដែលប្រមូលផ្តុំគ្នាខ្លាំង ឧ. ត្រីផ្សេងទៀតដែលមិនមានបញ្ជាក់ឈ្មោះប្រភេទជាក់លាក់ តំណាង ១១,៨% និងភាគច្រើនដោយសារការរួមចំណែក នៃត្រីល្អិតចម្រុះ (៧,៣%) កំពឹសចម្រុះ (២,៣%) និងវារីសត្វល្អិត (២,០%)។ ការរួមចំណែកនៃត្រីផ្សេងទៀត មានត្រឹម ០,២% នៃផលនេសាទសរុប។

**តារាងទី១៣.** តម្លៃ (១០០០រៀល) សមាមាត្រតម្លៃ និងថ្លៃជាមធ្យមនៃប្រភេទកំពូលគេទាំង២០ សម្រាប់ឆ្នាំ២០២៣

| | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាខ្មែរ | តម្លៃ (១០០០រៀល) | %តម្លៃ | ថ្លៃ (រៀល) |
|---|---|---|---|---|---|
| 1 | *Puntioplites proctozysron* | ត្រីច្រកែង | ១៣.៧៩២,៤ | ១២,០% | ៦.៤២៥ |
| 2 | *Channa striata* | ត្រីរ៉ស់/ផ្ទក់ | ១២.២៧៦,៦ | ១០,៧% | ១១.១០០ |
| 3 | *Hemibagrus spilopterus* | ត្រីឆ្លាំង | ៤.៩៦២,៨ | ៤,៣% | ១០.៧០០ |
| 4 | *Henicorhynchus siamensis* | ត្រីរៀលតុប | ៤.៨៦០,៩ | ៤,២% | ៦.៤៧៥ |
| 5 | *Macrognathus siamensis* | ត្រីខ្លួញ | ៤.៤៦៩,៣ | ៣,៩% | ១៤.១២៥ |
| 6 | *Hypsibarbus malcolmi* | ត្រីឆ្ពិនមូល | ៤.៣៥១,៩ | ៣,៨% | ៥.៦០០ |
| 7 | *Somanniathelphusa sp.* | ក្តាមស្រែ | ៤.២៨៧,៣ | ៣,៧% | ២.៧៥០ |
| 8 | *Mystus singaringan* | ត្រីកញ្ចុះបាយស | ៤.១៧៥,៣ | ៣,៦% | ៦.២០០ |
| 9 | *Barbonymus gonionotus* | ត្រីឆ្ពិនប្រាក់ | ៣.៧៩០.៣ | ៣,៣% | ៨.២២៥ |
| 10 | *Cyclocheilichthys enoplos* | ត្រីឆ្កោក | ៣.៦៧៩,៥ | ៣,២% | ១១.០៥០ |
| 11 | *Mystus mysticetus* | ត្រីកញ្ចុះឆ្នូត | ៣.៥៩៨,៥ | ៣,១% | ៦.៨៥០ |
| 12 | *Anabas testudineus* | ត្រីក្រាញ់ | ៣.៥៧១,១ | ៣,១% | ៦.២២៥ |
| 13 | *Mixed small or juvenile fish* | ត្រីល្អិតចម្រុះ | ៣.៤៥៦,៩ | ៣,០% | ៤.៦២៥ |
| 14 | *Notopterus notopterus* | ត្រីស្លាត | ៣.១៦០,៧ | ២,៨% | ៦.៧២៥ |
| 15 | *Henicorhynchus lobatus* | ត្រីរៀលអង្កាម | ២.៣៧៨,៦ | ២,១% | ៥.១២៥ |
| 16 | *Osteochilus lini* | ត្រីក្រុស | ១.៨១២,៧ | ១,៦% | ៥.៦៥០ |
| 17 | *Small mixed shrimps* | កំពឹសចម្រុះ | ១.៧៩៤,៩ | ១,៦% | ៦.៣០០ |
| 18 | *Aquatic insects nei* | វារីសត្វល្អិតគ្មានក្នុងក្រុមដំទៃ | ១.៤៥២,១ | ១,៣% | ៣.២២៥ |
| 19 | *Micronema sp.* | ត្រីកែស | ១.៤២៧,៥ | ១,២% | ១៥.១២៥ |
| 20 | *Henicorhynchus lobatus* | ត្រីរៀលអង្កាម | ២.៣៧៨,៦ | ២,១% | ៥.១២៥ |
| | Other species | ប្រភេទផ្សេងទៀត | ២៨.៧៤៤,៨៤ | ២៥,១% | |
| | **តម្លៃសរុប** | | **១១៤.៥៧៨,៦** | | |

ផលនេសាទតាមតម្លៃមានរួមបញ្ចូលក្នុង**តារាងទី១៣** សម្រាប់ប្រភេទកំពូលគេទាំង ២០ តំណាងឱ្យជិត ៧៥% នៃតម្លៃសរុប ដែលបង្ហាញពីចំនួនប្រភេទដែលមានសារៈសំខាន់សេដ្ឋកិច្ច។ តម្លៃនេះ គឺផ្អែកលើតែតម្លៃលក់ជាក់ស្តែង នៅពេលដែលផលនេសាទមួយផ្នែកឬទាំងអស់ត្រូវបានលក់។

## ៣.ការពិភាក្សានិងអនុសាសន៍

### ៣.១ ការពិភាក្សា

ដោយសារជំនួយថវិការបស់សហភាពអឺរ៉ុបទម្លាក់យឺត ការចាប់ផ្តើមប្រមូលទិន្នន័យតាមដានផលនេសាទត្រូវបានពន្យារពេល បើប្រៀបធៀបទៅនឹងឆ្នាំ២០២២ ហើយការប្រមូលទិន្នន័យត្រូវបានអនុវត្តចាប់ពីខែមិថុនាដល់ខែធ្នូ ឆ្នាំ ២០២៣ ជាមួយនឹងការសម្ភាសសំណាកត្រូវបានកាត់បន្ថយយ៉ាងច្រើនសម្រាប់ខែធ្នូ។ មិនមានការប្រមូលទិន្នន័យក្នុងរយៈពេល៥ខែដំបូងនៃឆ្នាំ២០២៣។ ជាលទ្ធផល សំណាកគំរូមិនអាចតំណាងបានត្រឹមត្រូវដល់ការប្រែប្រួលផលនេសាទតាមរដូវ។ ក៏ប៉ុន្តែ ដោយការរួមបញ្ចូលគំរូគ្រួសារក្នុងទំហំពេញលេញពីតំបន់ឆ្នេរ និងតំបន់ភ្នំ និងដោយមានសំណាកភូមិ និងគ្រួសារខ្ពស់ជាងភូមិនៅតំបន់ផ្សេងទៀត ធ្វើឱ្យការវាយតម្លៃផលនេសាទទឹកសាបសម្រាប់ឆ្នាំ២០២៣ មានការគ្របដណ្តប់ប្រសើរជាងការស្ទង់មតិឆ្នាំ២០២១ និងឆ្នាំ២០២២។ ទាំងចំនួនភូមិគោលដៅ និងចំនួនគ្រួសារដែលត្រូវបានសម្ភាសជារៀងរាល់ខែកើនឡើងទ្វេរដង។

ការជ្រើសរើសសំណាកគំរូសម្រាប់ឆ្នាំ២០២៣ គ្របដណ្តប់បានល្អនៅតាមតំបន់នេសាទទាំងអស់ ប៉ុន្តែមិនបានតំណាងឱ្យត្រឹមត្រូវតាមរដូវកាល រួមទាំងភូមិមួយចំនួនក្នុងខេត្តរតនគិរី (ដែលគ្របដណ្តប់ផ្នែកខ្លះនៃដែនទឹកសម្រាប់ដៃទន្លេសំខាន់ៗទាំងបីនៃទន្លេមេគង្គ)។ តំបន់ភ្នំត្រូវបានគ្របដណ្តប់ក្នុងខេត្តត្បូងឃ្មុំ និងកំពង់ស្ពឺ ដែលមានភូមិគោលដៅចំនួន៣។ ខេត្តកំពត ត្រូវបានយកជាតំណាងឱ្យការនេសាទនៅខេត្តកោះកុង និងខេត្តព្រះសីហនុផងដែរ។ ការប្រមូលទិន្នន័យឆ្នាំ២០២៣ មានភាពប្រសើរឡើងច្រើនជាងការប្រមូលទិន្នន័យឆ្នាំ២០២១-២០២២ ដោយទិន្នន័យដែលបានប្រមូល ផ្តល់នូវភាពតំណាងច្រើនជាង និងមានព័ត៌មានសម្រាប់ផលផលទឹកសាបទាំងមូល។ ទោះបីជាការគ្របដណ្តប់តាមផ្នែកខ្លះមានលក្ខណៈល្អប្រសើរក៏ដោយ ក៏ការប្រមូលទិន្នន័យបានអនុវត្តក្នុងរយៈពេលខ្លីត្រឹម ៦ខែ ចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា ឆ្នាំ២០២៣។ នេះមានន័យថា លទ្ធផលទទួលបានពីការអនុវត្តឆ្នាំ២០២៣ ទោះបីជាអាចតំណាងឱ្យនេសាទទឹកសាបទាំងមូលយ៉ាងណាក្តី ក៏មិនអាចប្រើដើម្បីបង្ហាញពីភាពខុសគ្នាតាមរដូវ ខណៈដែលភាពសម្បូរនៃត្រីមានច្រើន គឺអាស្រ័យលើទឹកជំនន់តាមរដូវ ដូចដែលបានចង្អុលបង្ហាញខាងលើ។ ទិន្នន័យប្រមូលបាន មិនសមស្របក្នុងការផ្តល់ការប៉ាន់ប្រមាណផលនេសាទសរុបពេញមួយឆ្នាំ។ បើប្រៀបធៀបទៅនឹងការវិភាគឆ្នាំ ២០២២ គឺមានការកែលម្អជាច្រើនអាចកត់សម្គាល់បាន រួមមានទិន្នន័យឆ្នាំ២០២៣ បានរួមបញ្ចូលប្រភេទច្រើនជាងមុន មានសមាមាត្រនៃ OAA ខ្ពស់ជាងមុន (ជាមួយនឹងការរួមបញ្ចូលវារីវប្បជាតិ) និងបានកាត់បន្ថយនូវភាពលំអៀងនៃសំណាកគំរូដែលធ្វើឱ្យការប៉ាន់ប្រមាណខុសលើការនេសាទដោយមិនប្រើទូក។

ដោយសារតែការប្រែប្រួលនៃធនធានផលផល គឺអាស្រ័យតាមរដូវ នោះការប៉ាន់ប្រមាណនៃផលនេសាទមិនអាចគណនាអោយបានត្រឹមត្រូវពេញមួយឆ្នាំនោះទេ ពីព្រោះទិន្នន័យដែលអាចប្រើ គឺបានគ្របដណ្តប់តែរដូវទឹកជំនន់ ដែលច្រើនតែមានផលិតភាពនេសាទខ្ពស់ប៉ុណ្ណោះ។ ការពង្រីកការប៉ាន់ប្រមាណផលនេសាទសរុបយោងលើទិន្នន័យ ដែលមានពីខែមិថុនាដល់ខែវិច្ឆិកា អោយបានដល់ពេញមួយឆ្នាំ នាំអោយការប៉ាន់ប្រមាណមិនត្រឹមត្រូវ ខណៈដែលការសន្មត់យកផលនេសាទមធ្យមពីខែមេសា ដល់ខែឧសភា ក្នុងឆ្នាំ២០២២ (៣៣.៣៥០តោន) សម្រាប់ធ្វើការប៉ាន់ប្រមាណផលនេសាទ នៅចន្លោះខែមករា ដល់ខែឧសភា និងខែធ្នូ ដែលជាខែមិនមានទិន្នន័យ នាំឱ្យមានការប៉ាន់

ប្រមាណផលនេសាទសរុបមានចំនួន **៤៨៩.៤២៣តោន** នៅឆ្នាំ២០២៣។ ការប៉ាន់ប្រមាណនេះទំនងជានៅតែជាការប៉ាន់ប្រមាណមិនត្រឹមត្រូវ ហើយកម្រិតពិតប្រាកដនៃទិន្នផលប្រចាំឆ្នាំ មិនអាចប៉ាន់ស្មានបាន។

ដោយផ្អែកលើផលនេសាទតាមទីជម្រក ប្រមាណ៣២,៩% នៃផលនេសាទត្រូវបានចាប់នៅក្នុងទីជម្រកទំនាបលិចទឹក ដែលជាប់ទាក់ទងទៅវាលស្រែ (រួមទាំងប្រឡាយធារាសាស្ត្រ) ចំណែកឯស្ថិតិផ្លូវការរបស់រដ្ឋបាលជលផលគឺ ៣៧,០%។

**តារាងទី១៤.** ការប្រៀបធៀបផលនេសាទសរុបផ្លូវការឆ្នាំ២០២៣ ជាមួយនឹងការប៉ាន់ប្រមាណតាមមូលដ្ឋាន CAS (តោន)

| **នេសាទទឹកសាប** | **ទិន្នន័យរបស់** FiA DPFIC | | **ទិន្នន័យ** CAS **ដោយ** IFReDI |
|---|---|---|---|
| នេសាទជាយត្រី | ១៣.៦៥០ | | |
| នេសាទគ្រួសារ (ដែននេសាទធម្មជាតិ) | ២៦០.៣០០ | ៦៣% | ៧៧.១% |
| នេសាទគ្រួសារ (វាលស្រែ) | ១៥២.៨០០ | ៣៧% | ៣២,៩% |
| **សរុប** | **៤២៦.៧៥០** | | ***៤៨៩.៤២៣*** |

កន្លែងនេសាទតាមវាលស្រែរួមមានៈ វាលស្រែ ជម្រកព្រៃលិចទឹក និងប្រឡាយស្រោចស្រព។ ភាគរយរបស់ FiA DPFIC សំដៅលើការនេសាទជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ ដើម្បីអាចធ្វើការប្រៀបធៀបទៅនឹងលទ្ធផលរបស់ IFReDI CAS។

ការប៉ាន់ប្រមាណផ្លូវការឆ្នាំ២០២៣ ដែលត្រូវបានចេញផ្សាយដោយរដ្ឋបាលជលផល គឺ៤២៦.៧៥០ តោន សម្រាប់នេសាទទឹកសាប (តារាងទី១៤) ជាមួយនឹងនេសាទគ្រួសារមាន ៤១៣.១០០តោន ត្រូវបានគ្របដណ្តប់ដោយ CAS ។ ទិន្នន័យទាំងនេះ គឺជាស្ថិតិនេសាទប៉ុណ្ណោះ ហើយនេះគឺជាសូចនាករមិនល្អសម្រាប់ស្ថានភាពនិងនិន្នាការនៃនេសាទទឹកសាប។ ទោះជាយ៉ាងណា ក៏វាគឺជាព័ត៌មានមួយសម្រាប់ធ្វើការប្រៀបធៀបទិន្នផលសរុបរវាងស្ថិតិជលផលរបស់រដ្ឋបាលជលផល និង IFReDI CAS ដែលព័ត៌មានទាំងនេះផ្តល់ជាមូលដ្ឋានក្នុងការពិនិត្យលើការពាក់ព័ន្ធនឹងនេសាទ និងការពឹងផ្អែកលើនេសាទ ព័ត៌មានលម្អិតអំពីប្រភេទ សមត្ថភាពចាប់តាមឧបករណ៍និងតាមទីជម្រក និង CPUE (ផលនេសាទប្រចាំថ្ងៃ)។ ទាំងនេះ គឺជាសូចនាករដែលល្អសម្រាប់ជាមូលដ្ឋានក្នុងវាយតម្លៃស្ថានភាពនៃធនធានជលផលឱ្យកាន់តែប្រសើរឡើង។

**តារាងទី១៥.** ផលនេសាទប្រចាំថ្ងៃជាមធ្យម សមត្ថភាពចាប់ និងសមាមាត្រនៃគ្រួសារនេសាទសកម្ម តាមខេត្ត និងខែ សម្រាប់ខែមិថុនា-វិច្ឆិកា ឆ្នាំ២០២៣

| **តំបន់នេសាទ** | **ខេត្ត** | **គ្រួសារសកម្ម** | **សមត្ថភាពចាប់ប្រចាំខែ (ថ្ងៃ)** | **CPUE (គ.ក្រ/ថ្ងៃ)** | **ε%** | **ផលនេសាទប្រចាំខែតាមគ្រួសារ (គ.ក្រ)** |
|---|---|---|---|---|---|---|
| ឆ្នេរ | កំពត | ៤៦,៣% | ១៣,៩ | ២,៣៤ | ៨,៤% | ៣២,៦ |
| ទំនាបលិចទឹក | កំពង់ចាម | ៤៨,៩% | ១៦,៧ | ៤,១៩ | ៧,៤% | ៧០,១ |
| ទំនាបលិចទឹក | កណ្តាល | ៤៨,១% | ១៧ | ២,៦៦ | ៨,៣% | ៤៥,២ |
| ទំនាបលិចទឹក | ព្រៃវែង | ៤១,៧% | ១១ | ២,៨៤ | ៥,៦% | ៣១,៣ |
| ទំនាបលិចទឹក | ស្វាយរៀង | ៦១,១% | ១២,១ | ២,២២ | ៦,២% | ២៧ |

| | | | | | | |
|---|---|---|---|---|---|---|
| ទំនាបលិចទឹក | តាកែវ | ៤៧,២% | ១៣,៣ | ២,៣២ | ៩,២% | ៣០,៨ |
| ខ្ពង់រាប | ក្រចេះ | ៧៨,៥% | ១៥ | ២,៤៥ | ៦,៦% | ៣៦,៨ |
| ខ្ពង់រាប | រតនគិរី | ៧១,៧% | ១៣,៨ | ២,៩៩ | ៨% | ៤១,២ |
| ខ្ពង់រាប | ស្ទឹងត្រែង | ៦៩,៦% | ១៩,៧ | ៥,១២ | ៦,៤% | ១០០,៧ |
| ទន្លេសាប | បន្ទាយមានជ័យ | ៥៩,១% | ១៣,៤ | 4.03 | ១៤,៧% | ៥៣,៩ |
| ទន្លេសាប | បាត់ដំបង | ៧១,៦% | ១៤,៩ | 3.63 | ១១,២% | ៥៤,១ |
| ទន្លេសាប | កំពង់ឆ្នាំង | ៦១,២% | ១៨,៧ | 5.74 | ៨,១% | ១០៧,៦ |
| ទន្លេសាប | កំពង់ធំ | ៤៩,២% | ១៧,៨ | 2.42 | ៧,២% | ៤៣,១ |
| ទន្លេសាប | ពោធិ៍សាត់ | ៦៩,២% | ១៩ | 8.46 | ៨,៥% | ១៦១ |
| ទន្លេសាប | សៀមរាប | ៥៣,៥% | ១៨,៣ | 6.85 | ១៣,២% | ១២៥,៧ |
| ភ្នំ | កំពង់ស្ពឺ | ៥៤,៤% | ១៤,៦ | 2.49 | ៦,១% | ៣៦,៤ |
| ភ្នំ | ត្បូងឃ្មុំ | ៦៧,៧% | ២០,១ | 5.24 | ៧,៦% | ១០៥,២ |
| **សរុប** | | **៥៨,១%** | **១៦** | **៣,៩៦** | **២,៧%** | **៦៣,៥** |

តារាងទី១៥ បង្ហាញពីការប្រៀបធៀបនៃសូចនាករផលនេសាទនិងសមត្ថភាពចាប់សំខាន់ៗ បានបង្ហាញពីភាពខុសគ្នារវាងខេត្តនិងខេត្ត។ ការដាក់ស្រមោលលើតម្លៃ ធ្វើអោយមានភាពងាយស្រួលសម្គាល់តម្លៃខ្ពស់បំផុតសម្រាប់សូចនាករនីមួយៗ។ ខេត្តក្រចេះមានសមាមាត្រគ្រួសារនេសាទសកម្មខ្ពស់បំផុត ៧៨,៥% បន្ទាប់មកគឺខេត្តរតនគិរី បាត់ដំបង ស្ទឹងត្រែង និងពោធិ៍សាត់ ដែលមានតម្លៃប្រហាក់ប្រហែលគ្នា។ ខេត្តត្បូងឃ្មុំ មានសមត្ថភាពចាប់ប្រចាំខែខ្ពស់បំផុត (២០,១ថ្ងៃ) ប្រហាក់ប្រហែលនឹងខេត្តស្ទឹងត្រែង និងខេត្តពោធិ៍សាត់។ ដោយឡែក CPUE (ផលចាប់ប្រចាំថ្ងៃ) គឺខ្ពស់បំផុតនៅខេត្តពោធិ៍សាត់(៨,៤៦គ.ក្រ/ថ្ងៃ) បន្ទាប់មកខេត្តសៀមរាប(៦,៤៨គ.ក្រ/ថ្ងៃ)។ ផលនេសាទមធ្យមតាមគ្រួសារប្រចាំខែ ទទួលបានពីការយកការនេសាទគុណជាមួយ CPUE។ ជាលទ្ធផល ខេត្តពោធិ៍សាត់មានផលនេសាទមធ្យមប្រចាំខែខ្ពស់ជាងគេ (១៦១គីឡូក្រាម) បន្ទាប់មកខេត្តសៀមរាប (១២៥,៧ គីឡូក្រាម) និងផលនេសាទមធ្យមប្រចាំខែប្រហែល ១០០-១០៥ គីឡូក្រាមមាននៅខេត្តកំពង់ឆ្នាំង ស្ទឹងត្រែង និងត្បូងឃ្មុំ។

ជាការកត់សម្គាល់ តម្លៃខាងលើគឺតំណាងឱ្យពីខែមិថុនា ដល់ខែវិច្ឆិកា ដែលជារយៈពេលមានផលនេសាទខ្ពស់បំផុត តម្លៃភាគច្រើនហាក់ដូចជាឆ្លុះបញ្ចាំងនឹងតម្លៃពិត ប៉ុន្តែតម្លៃខ្ពស់នៃផលនេសាទមធ្យមមួយចំនួនហាក់ដូចជាមិនតំណាងឱ្យខេត្តទាំងមូល ឧ.ខេត្តត្បូងឃ្មុំ និងខេត្តផ្សេងទៀត ដែលមានភូមិគោលដៅភាគច្រើនជាភូមិនៅតំបន់មាត់ទន្លេ។ ការគ្រោងយកសំណាកគំរូមិនមានបំណងប្រើដើម្បីប៉ាន់ប្រមាណតាមខេត្ត ប៉ុន្តែធ្វើការប៉ាន់ប្រមាណតាមតំបន់នេសាទ។ លើសពីនេះ ដោយសារតែ CAS អនុវត្តការសម្ភាសតាមបែបរំលឹកឡើងវិញ អ្នកឆ្លើយតបសំណួរមួយចំនួនមិនចងចាំបានត្រឹមត្រូវ ជាពិសេសនៅក្នុងតំបន់នេសាទ ដែលមានកម្រិតពឹងផ្អែកលើការនេសាទតិចតួច ដូចជានៅតំបន់ដីគោកដែលឆ្ងាយពីទីជម្រកវារីជាតិសំខាន់ៗ។

ទំហំសំណាកកាន់តែខ្ពស់នាំអោយមានរបាយសំណាក និងភាពតំណាងកាន់តែប្រសើរ ការប៉ាន់ប្រមាណផលនេសាទតាមឧបករណ៍ ទីជម្រក (និងសមត្ថភាពចាប់) និងតាមតំបន់នេសាទភាគច្រើនមានភាពត្រឹមត្រូវតាមបែបស្ថិតិក្នុងអំឡុងពេលនៃការធ្វើសម្ភាសវាយតម្លៃផលនេសាទ។ ការប៉ាន់ប្រមាណផលនេសាទប្រចាំខែ តាមខេត្ត (**តារាងទី១៦**) ត្រូវបានគណនាដោយផ្អែកលើទំហំសំណាកបច្ចុប្បន្ន ប៉ុន្តែនៅតាមខែ និងខេត្តមួយចំនួនមិនបំពេញបានតាមន័យស្ថិតិ។ លើសពីនេះ របាយភូមិគោលដៅអាចនឹងមិនផ្តល់តំណាងពេញលេញសម្រាប់ខេត្តទាំងមូល ដែលបណ្តាលឱ្យមានភាពលំអៀងនៃសំណាកគំរូ។ ការប៉ាន់ប្រមាណតម្លៃ ៩% ខ្ពស់ មានច្រើននៅខែមិថុនា នេះបង្ហាញថា វាអាចជាបញ្ហាប្រឈមជាក់លាក់នឹងកើតមានឡើងសម្រាប់រដូវប្រាំង នៅពេលដែលមានគ្រួសារអ្នកនេសាទចូលរួមក្នុងការនេសាទតិចជាង រួមនឹងបម្រែបម្រួលខ្ពស់នៃផលនេសាទ។ ទាំងនេះ គឺដោយសារតែកម្រិតកំណត់នៃឱកាសនេសាទ នៅពេលដែលជម្រកទំនាបលិចទឹករីងស្ងួត។ យ៉ាងណាមិញ ការបង្កើនទំហំសំណាកគំរូនឹងអាចឱ្យគេអាចធ្វើការប៉ាន់ប្រមាណផលនេសាទ និងសមត្ថភាពចាប់នៅថ្នាក់ខេត្តបាន។ ចំនួនភូមិគោលដៅត្រូវបង្កើនបន្ថែមសម្រាប់តំបន់ទំនាបលិចទឹកនិងទន្លេសាប និងបន្ថែមការគ្របដណ្តប់សម្រាប់ខេត្តតំបន់ឆ្នេរនិងភ្នំតំបន់ភ្នំអោយបានចំនួន៦ភូមិ (ដោយមិនរួមបញ្ចូលខេត្តកែប) ដែលបច្ចុប្បន្នមិនត្រូវបានរាប់បញ្ចូល។ ការរចនាសំណាកគំរូជាក់លាក់គឺអាស្រ័យលើតម្រូវការប៉ាន់ប្រមាណពិតប្រាកដ ដូចមានបង្ហាញក្នុង**តារាងទី១៦** ទំហំសំណាកគ្រួសារគំរូ ដែលត្រូវបានស្នើឡើង មានចំនួនជិត ១៦០០ គ្រួសារ ក្នុងចំនួននេះនឹងអនុញ្ញាតឱ្យមានការប៉ាន់ប្រមាណ CPUE (ការចាប់ប្រចាំថ្ងៃ) និងសមត្ថភាពចាប់តាមខេត្តប្រចាំខែ បានពេញមួយឆ្នាំ ក៏ប៉ុន្តែមិនអាចធានាបានថាការប៉ាន់ប្រមាណផលនេសាទតាមឧបករណ៍និងទីជម្រកផ្សេងៗនឹងតែងតែមានសុពលភាពតាមបែបស្ថិតិ។

**តារាងទី១៦.** តម្លៃ CPUE តាមគ្រួសារ ដែលត្រូវបានប៉ាន់ប្រមាណ (គ.ក្រ/ថ្ងៃ) និងទំហំសំណាកបច្ចុប្បន្ន និងទំហំសំណាក ដែលត្រូវបានណែនាំ តាមខេត្តនីមួយៗ

| តំបន់នេសាទ | ខេត្ត | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | សំណាក ឆ្នាំ ២០២៣ | សំណាក តាមខេត្ត |
|---|---|---|---|---|---|---|---|---|---|
| ឆ្នេរ | កំពត | ២,៣២ | ២,៦១ | ២,០៥ | ២,២៤ | ២,៤៦ | ២,៣៦ | ៤៥ | ៦០ |
| ទំនាបលិចទឹក | កំពង់ចាម | ៤,២៦ | ៤,៤០ | ៣,៩៦ | ៦,០២ | ១,៨០ | ៣,៧៩ | ៦០ | ៩០ |
| ទំនាបលិចទឹក | កណ្តាល | ៣,៦២ | ៤,២៩ | ១,៨៨ | ២,៣៥ | ២,២៥ | ២,៣១ | ៤៥ | ៧៥ |
| ទំនាបលិចទឹក | ព្រៃវែង | ១,៥០ | ១,៨៦ | ២,៤០ | ៣,៤៥ | ២,៩៦ | ២,៨៨ | ៦០ | ៩០ |
| ទំនាបលិចទឹក | ស្វាយរៀង | ១,២៣ | ២,៤០ | ៣,៥១ | ១,៦៦ | ១,៩៨ | ១,៩៨ | ៤៥ | ៧៥ |
| ទំនាបលិចទឹក | តាកែវ | ២,៦២ | ៣,០៦ | ៣,១៨ | ១,៤៩ | ២,៣២ | ១,៦៧ | ៤៥ | ៧៥ |
| ខ្ពង់រាប | ក្រចេះ | ៤,១២ | ១,៩២ | ២,៧៣ | ២,១៤ | ២,០៦ | ២,២២ | ៤៥ | ៤៥ |
| ខ្ពង់រាប | រតនគិរី | ៣,២៣ | ២,៥៥ | ៤,៩៩ | ២,១៥ | ២,៧៩ | ២,០៩ | ៤៥ | ៤៥ |
| ខ្ពង់រាប | ស្ទឹងត្រែង | ៩,២៣ | ៧,០៩ | ៤,៦២ | ៤,០៥ | ៤,៣៦ | ២,៩០ | ៤៥ | ៤៥ |
| ទន្លេសាប | បន្ទាយមានជ័យ | ៤,៩៨ | ១,៩៥ | ២,៥៦ | ២,០៦ | ៦,២១ | ៤,៥៩ | ៤៥ | ៧៥ |
| ទន្លេសាប | បាត់ដំបង | ៤,១៧ | ៤,៥៤ | ១,៨៦ | ៣,៨១ | ២,៣០ | ៤,៥៤ | ៦០ | ៩០ |
| ទន្លេសាប | កំពង់ឆ្នាំង | ៦,៤៣ | ៣,៨០ | ៥,៧៨ | ៥,៤៤ | ៧,២០ | ៤,៥០ | ៤៥ | ៧៥ |

| **តំបន់នេសាទ** | **ខេត្ត** | **មិថុនា** | **កក្កដា** | **សីហា** | **កញ្ញា** | **តុលា** | **វិច្ឆិកា** | **សំណាក ឆ្នាំ ២០២៣** | **សំណាកតាមខេត្ត** |
|---|---|---|---|---|---|---|---|---|---|
| ទន្លេសាប | កំពង់ធំ | ៣,២១ | ៣,០៤ | ២,៦៣ | ១,៨៥ | ១,៩៩ | ២,២៤ | ៤៥ | ៧៥ |
| ទន្លេសាប | ពោធិសាត់ | ៧,២៣ | ៧,៤៩ | ៦,៩៦ | ១១,៣៤ | ៩,៤៩ | ៣,៦៩ | ៤៥ | ៧៥ |
| ទន្លេសាប | សៀមរាប | ១១,៧២ | ១២,១៥ | ៥ | ៥,១៩ | ៥,០៥ | ៥,៥៤ | ៦០ | ៩០ |
| ភ្នំ | កំពង់ស្ពឺ | ៣,៤៤ | ២,១៥ | ២,៣៤ | ២,៥៧ | ២,៤៣ | ២,៥៤ | ៤៥ | ៧៥ |
| ភ្នំ | ត្បូងឃ្មុំ | ៦,២៨ | ៣,៤០ | ៥,៤៩ | ៥,៥៨ | ៥,០៥ | ៥,៤៧ | ៦០ | ៦០ |
| ឆ្នេរ | នៅខេត្ត ២ទៀតមិនទាន់បានគ្របដណ្តប់ | | | | | | | | ១២០ |
| ភ្នំ | នៅខេត្ត ៤ទៀតមិនទាន់បានគ្របដណ្តប់ | | | | | | | | ២៤០ |
| **សំណាកគ្រួសារសរុប** | | | | | ៨៤០ | | | | **១.៥៧៥** |

ការរៀបចំសំណាកបច្ចុប្បន្នសម្រាប់ការអនុវត្ត CAS ក្នុងឆ្នាំ២០២៣ ជាជម្រើសមួយដោយសារពេលវេលា និងធនធានមានកម្រិត។ ការធ្វើវិមជ្ឈការនៃការប្រមូលទិន្នន័យទៅខណ្ឌរដ្ឋបាលជលផលនឹងជួយបង្កើនវិសាលភាពនៃការប្រមូលទិន្នន័យប្រចាំខែបានជាប្រចាំ និងផ្តល់នូវការគ្របដណ្តប់កាន់តែប្រសើរ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍ស្ថិតិ។ យ៉ាងណាមិញ កម្រិតប្រមូលទិន្នន័យដែលបានស្នើឡើង ទំនងជាមិនអាច អនុវត្តបានជាប្រចាំដោយមន្ត្រីថ្នាក់ខេត្តឡើយ ដោយសារតែការចំណាយ និងតម្រូវការមន្ត្រី។ ជាជម្រើស ការប្រើ លទ្ធផលទទួលបានពី CAS ជាធាតុចូលសម្រាប់ការពិនិត្យលម្អិតបន្ថែមទៀតអំពីស្ថានភាពនៃនេសាទទឹកសាប ក៏ដូចជាមធ្យោបាយដើម្បីវាយតម្លៃ និងបំពេញបន្ថែមដល់ទិន្នផលជលផលទូទៅ ដែលមានក្នុងស្ថិតិជលផលផ្លូវការ។ លទ្ធផលទទួលបានពី CAS ឆ្នាំ ២០២៣ ផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្ននៃនេសាទទឹកសាប ហើយអ្វីដែលចាំបាច់ គឺធ្វើការវាយតម្លៃនិន្នាការប្រែប្រួលសម្រាប់ CAS រៀងរាល់ ៣-៥ ឆ្នាំម្តង ទន្ទឹមគ្នានឹងកែលម្អកម្រិតលម្អិតនៅក្នុងស្ថិតិជលផល ជាពិសេសទាក់ទងនឹងផលនេសាទតាមប្រភេទ និងសមត្ថភាពចាប់ ក៏ដូចជាសកម្មភាពពាក់ព័ន្ធនឹងសកម្មភាពនេសាទ និងការពឹងផ្អែកលើនេសាទ។

## ៣.២ អនុសាសន៍

- IFReDI បានសម្រេចចិត្តមិនបន្តអនុវត្តការសម្ភាស CAS នៅក្រោយឆ្នាំ២០២៣ ទិន្នន័យសម្ពាតរួច និងរក្សាអនាមិកដល់អ្នកឆ្លើយតបសំនួរក្នុងការសម្ភាសជ្រើសរើសគ្រួសារ (HIS) និងការសម្ភាសផលនេសាទតាមគ្រួសារ (HCI) រួមនឹងឯកសារពេញលេញដែលចាំបាច់ត្រូវបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាន (FIMS) ដើម្បីផ្តល់ភាពងាយស្រួលក្នុងការចូលទៅប្រើទិន្នន័យ និងសម្រាប់ធ្វើការវិភាគឱ្យបានកាន់តែស៊ីជម្រៅ
- ប្រសិនបើ CAS នឹងត្រូវបានអនុវត្តនៅចន្លោះពេល ៣- ឬ ៥ ឆ្នាំ ចាំបាច់ត្រូវរៀបចំសំណាកគំរូគ្រួសារទាំងអស់ឡើងវិញ ដើម្បីអាចធ្វើការវាយតម្លៃសមាមាត្រគ្រួសារដែលមិនធ្វើនេសាទ និងការពឹងផ្អែកលើការនេសាទរបស់គ្រួសារធ្វើនេសាទដែលជាសូចនាករមួយសំខាន់សម្រាប់វាយតម្លៃអំពីតួនាទីនៃនេសាទដល់ប្រាក់ចំណូល និងសន្តិសុខស្បៀង

- IFReDI ត្រូវធ្វើការរៀបចំគម្រោងដើម្បីធានានូវថវិកាដែលអាចគ្របដណ្ដប់សម្រាប់ការអនុវត្ត CAS រៀងរាល់ ៣- ឬ ៥-ឆ្នាំ ដែលជាពេលវេលានៃការអង្កេតវាយតម្លៃជលផល
- IFReDI ចាំបាច់ត្រូវចូលរួមនៅក្នុងការសម្រេចចិត្តលើសូចនាករសម្រាប់ការត្រួតពិនិត្យជលផល និងវាយតម្លៃប្រសិទ្ធភាពនៃអន្តរាគមន៍គ្រប់គ្រង រួមទាំងចំណុចផ្ដោតសំខាន់ៗសម្រាប់ស្ថិតិជលផល។ ដំណើរការនេះតម្រូវឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ (DPFIC) ជាពិសេសទាក់ទងនឹងការរៀបចំផែនទីបង្ហាញផ្លូវសម្រាប់យុទ្ធសាស្ត្រជាតិសម្រាប់ការប្រមូលទិន្នន័យជលផលនិងវារីវប្បកម្ម ក្រោមក្រុមការងារនៃរដ្ឋបាលជលផលស្ដីពីការគ្រប់គ្រងស្ថិតិនិងព័ត៌មាន (WSIM)
- IFReDI គួរតែបង្កើតយុទ្ធសាស្ត្រមួយជម្រុញឱ្យប្រើលទ្ធផលទទួលបានពីការអនុវត្ត CAS ដើម្បីជួយកែលម្អស្ថិតិជលផលទឹកសាបផ្លូវការ ដោយមានការគាំទ្របច្ចេកទេសពី FAO CAPFISH ដើម្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយ DPFIC ដើម្បីឈានដល់ការឯកភាពគ្នាលើរបៀបដែលលទ្ធផល CAS ត្រូវបានប្រើប្រាស់ដើម្បីបង្កើនស្ថិតិជលផលជាតិ
- ប្រសិនបើការប្រមូលទិន្នន័យអំពីផលនេសាទ និងសមត្ថភាពចាប់ត្រូវបានអនុវត្តដោយមន្ត្រីនៃខណ្ឌរដ្ឋបាលជលផល ចាំបាច់ត្រូវមានការការអនុវត្តសាកល្បងក្នុងកំឡុងឆ្នាំ២០២៤ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីមន្ត្រីនៃIFReDI នៅមុនពេលធ្វើការសម្រេចចិត្តលើការដាក់ឱ្យដំណើរការនៅគ្រប់ខេត្តទាំងអស់។ ដំណើរការនេះតម្រូវឱ្យ៖
    - កំណត់ខេត្ត ដែលមានបំណងសាកល្បងវិធីសាស្ត្រ
    - ធ្វើការត្រួតពិនិត្យទម្រង់ប្រមូលទិន្នន័យសម្រាប់ប្រើប្រាស់ដោយខណ្ឌរដ្ឋបាលជលផឡើងវិញ ឧ. ដកចេញនូវសូចនាករទាំងឡាយណា ដែលមិនរួមចំណែកដល់ការប៉ាន់ប្រមាណផលនេសាទតាមប្រភេទ និងសមត្ថភាពចាប់៖ ការប្រើប្រាស់ឧបករណ៍ ការប្រើប្រាស់ផលនេសាទ ទីជម្រកនេសាទ និងការជាប់ពាក់ព័ន្ធនិងសកម្មភាពនេសាទដោយសមាជិកគ្រួសារ
    - សេចក្ដីត្រូវការសម្រាប់ធ្វើការប៉ាន់ប្រមាណផលនេសាទសរុបប្រចាំខែ និងស្ថិតិផ្សេងទៀតតាមខេត្ត (ដែលជាប់ពាក់ព័ន្ធដល់ទំហំ និងរបាយសំណាក
    - ការរៀបចំតាមសំណាកជាក្រុមៗ ដើម្បីសម្រេចថាតើរបាយសំណាកនៃសមត្ថភាពចាប់ និងរបាយសហគមន៍ផ្ដល់នូវទិន្នន័យកាន់តែប្រសើរ ឧទាហរណ៍ រៀបចំក្រុមសំណាកសម្រាប់តំបន់ដែនទឹកសាធារណៈ និងតំបន់វាលស្រែ (ទំនាបលិចទឹក)
- ជាមួយនឹងទំហំសំណាកគំរូគ្រួសារកាន់តែច្រើន ជាអនុសាសន៍ វាជាការចាំបាច់ខ្លាំងណាស់ក្នុងការពិនិត្យឡើងវិញនូវការវិភាគ ដោយប្រៀបធៀបការវាយតម្លៃដោយពឹងអាស្រ័យលើការនេសាទ (រួមបញ្ចូលក្នុងទិន្នន័យ HSI) សម្រាប់សំណាកគំរូឆ្នាំ២០២១-២០២២ ជាមួយនឹងសំណាកគំរូដែលត្រូវបានបង្កើននៅឆ្នាំ២០២៣ ក៏ដូចជាការប្រៀបធៀបទៅនឹងលទ្ធផលនៃការសម្ភាសការប្រើប្រាស់ផលនេសាទឆ្នាំ២០២៣-២០២៤ និងការសម្ភាសអំពីប្រាក់ចំណូល ដែលត្រូវបានគ្រោងសម្រាប់ឆ្នាំ២០២៣ និងឆ្នាំ២០២៤។ លទ្ធផលនៃការអង្កេតទាំងនេះអាចបង្ហាញឱ្យឃើញនូវការប្រែប្រួល និងសារៈសំខាន់នៃការប្រើប្រាស់ទូក សមត្ថភាពចាប់ និងផលនេសាទប្រចាំថ្ងៃ
- ការបែងចែកខេត្តតាមតំបន់នេសាទ ចាំបាច់ត្រូវពិនិត្យ និងធ្វើការសម្រេចចិត្តដូចខាងក្រោម៖
    - សម្រាប់ការវិភាគឆ្នាំ២០២២ ខេត្តកំពង់ស្ពឺត្រូវបានបញ្ចូលទៅក្នុងតំបន់ទន្លេសាប ប៉ុន្តែសម្រាប់ការវិភាគឆ្នាំ២០២៣ ត្រូវបានបន្ថែមទៅក្នុងតំបន់ភ្នំ
    - ខេត្តកំពង់ចាមត្រូវបានដាក់រួមបញ្ចូលនៅក្នុងតំបន់ទំនាបលិចទឹក ទោះបីជារដ្ឋបាលជលផល ដាក់ខេត្តនេះនៅក្រោមតំបន់មេគង្គ (ខ្ពង់រាប) ក៏ដោយ
    - ខេត្តបន្ទាយមានជ័យត្រូវបានដាក់រួមបញ្ចូលជាមួយតំបន់ទន្លេសាប ប៉ុន្តែខេត្តនេះស្រដៀងនឹងតំបន់ភ្នំ។

- ចាំបាច់ធ្វើការពិចារណាលើការពិនិត្យឡើងវិញ និងធ្វើស្តង់ដារនៃទីជម្រកនិងឧបករណ៍ ដើម្បីធានាថាគ្មានប្រភេទមិនមានបញ្ជាក់ជាក់លាក់ត្រូវបានរួមបញ្ចូលក្នុងទិន្នន័យ
- ដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃ CAS វាជាការចាំបាច់ក្នុងការធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីការវាយតម្លៃផលនេសាទទឹកសាប ដែលការរៀបចំសំណាកគំរូ ការគ្រប់ដណ្តប់ និងការចាត់ចំណាត់ថ្នាក់ ត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ ២០២១ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនានា
- របាយការណ៍សង្ខេប ឬអត្ថបទផ្សាយបែបវិទ្យាសាស្ត្រ គួរតែត្រូវបានរៀបចំ ដើម្បីពិពណ៌នាអំពី CAS និងលទ្ធផលដោយប្រើទិន្នន័យ ដែលប្រមូលបាននៅចន្លោះឆ្នាំ២០២១-២០២៣
- ជាចុងបញ្ចប់ ដូចដែលបានស្នើឡើងខាងលើ IFReDI គួរតែបង្កើតកម្មវិធីតាមដានរយៈពេលវែង នៅតំបន់ទន្លេមេគង្គលើ (ជម្រកត្រីមេពូជសំខាន់ៗ) និងបឹងទន្លេសាប (រួមចំណែកប្រហែល ៧០% ដល់ផលនេសាទប្រចាំឆ្នាំ) លើសុខភាពអេកូឡូស៊ី ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុលើប្រភេទជីវចម្រុះ និងការតភ្ជាប់នៃត្រីមេពូជសំខាន់ៗរវាងទន្លេបី ទន្លេមេគង្គ និងបឹងទន្លេសាប។

**ឧបសម្ព័ន្ធទី១.** ការបែងចែកខេត្តតាមតំបន់នេសាទនិងចំនួនគ្រួសារនេសាទ

| ខេត្ត | តំបន់នេសាទ | ជំរឿនប្រជាជនឆ្នាំ២០២៩ | | | គ្រួសារនេសាទនៅជនបទ | កំណត់ចំណាំ |
|---|---|---|---|---|---|---|
| | | សរុប | ទីក្រុង | ជនបទ | | |
| បន្ទាយមានជ័យ | ទន្លេសាប | ១៨៩.៥៨៨ | ៦៨.៦៦០ | ១២០.៩២៨ | ៥៨.៤១៦ | |
| បាត់ដំបង | ទន្លេសាប | ២២៧.២៣៧ | ៤៥.៥៥៦ | ១៨១.៦៨១ | ៨៧.៧៦៣ | |
| កំពង់ចាម | ទំនាបលិចទឹក | ២១៧.១៩៧ | ៣០.៣៨៦ | ១៨៦.៨១១ | ១៤៨.២៦៣ | ធម្មតារួមបញ្ចូលក្នុងអធិការដ្ឋានមេគង្គ |
| កំពង់ឆ្នាំង | ទន្លេសាប | ១២៦.២៩៩ | ២៨.៥២៣ | ៩៧.៧៧៦ | ៤៧.២៣២ | |
| កំពង់ស្ពឺ | ភ្នំ | ១៩៥.៨៨២ | ១១៤.៣៨០ | ៨១.៥០២ | ៣៩.៣៧១ | រួមបញ្ចូលក្នុងតំបន់ភ្នំ ទោះជាស្រដៀងនឹងតំបន់ទំនាបលិចទឹក |
| កំពង់ធំ | ទន្លេសាប | ១៦០.៧៦៦ | ១៦.១១៨ | ១៤៤.៦៤៨ | ៦៩.៨៧៤ | |
| កំពត | ឆ្នេរ | ១៤៣.៤០២ | ១៣.២៥៨ | ១៣០.១៤៤ | ៤៩.៩៧៥ | |
| កណ្តាល | ទំនាបលិចទឹក | ២៦៥.៨០៣ | ១៧០.៧៨២ | ៩៥.០២១ | ៧៥.៤១៣ | |
| កោះកុង | ឆ្នេរ | ២៨.០២៧ | ១២.៣៥៩ | ១៥.៦៦៨ | ៦.០១៧ | |
| ក្រចេះ | ខ្ពង់រាប | ៨៦.១៧៦ | ៩.២៩៧ | ៧៦.៨៧៩ | ៥១.៤១៦ | |
| មណ្ឌលគិរី | ភ្នំ | ២០.៤០៩ | ៧.៥០០ | ១២.៩០៩ | ៤.៣៦០ | |
| ភ្នំពេញ | | ៤៩៩.២៩៩ | ៤៩៩.២៩៩ | | | មិនរួមបញ្ចូលគ្រួសារទាំងអស់នៅទីក្រុង |
| ព្រះវិហារ | ភ្នំ | ៥៦.៧១៣ | ៥.៦៥០ | ៥១.០៦៣ | ១៧.២៤៦ | |

| | | | | | | |
|---|---|---|---|---|---|---|
| ព្រៃវែង | ទំនាបលិចទឹក | ២៦៦.៩៣៤ | ១៤.១៦៨ | ២៥២.៧៦៦ | ២០០.៦០៨ | |
| ពោធិសាត់ | ទន្លេសាប | ១០៣.៨៦២ | ១៧.៦២៤ | ៨៦.២៣៨8 | ៤១.៦៥៨ | |
| រតនគិរី | ខ្ពង់រាប | ៤៩.៧៤១ | ៦.៨៧៧ | ៤២.៨៦៤ | ២៨.៦៦៧ | |
| សៀមរាប | ទន្លេសាប | ២២៤.៦៧២ | ៦៧.៨៤៥ | ១៥៦.៨២៧ | ៧៥.៧៥៧ | |
| ព្រះសីហនុ | ឆ្នេរ | ៤៧.៣៨១ | ៣៤.០៦០ | ១៣.៣២១ | ៥.១១៥ | |
| ស្វាយរៀង | ទំនាបលិចទឹក | ១៣២.៤៩២ | ៣៧.២៨៥ | ៩៥.២០៧ | ៧៥.៥៦១ | |
| តាកែវ | ទំនាបលិចទឹក | ២០៨.៦៩៨ | ៦២.៨៥៦ | ១៤៥.៨៤២ | ១១៥.៧៤៨ | |
| ឧត្តមានជ័យ | ភ្នំ | ៦០.៨៨៦ | ១៩.៨២៦ | ៤១.០៦០ | ១៣.៨៦៨ | |
| កែប | ឆ្នេរ | ៩.៦០៥ | ៧.៧១៤ | ១.៨៩១ | ៧២៦ | មិនរួមបញ្ចូល ខេត្តកែបមានតែនេសាទសមុទ្រ |
| ប៉ៃលិន | ភ្នំ | ១៧.១៧៧ | ១៣.០៥០ | ៤.១២៧ | ១.៣៩៤ | |
| ត្បូងឃ្មុំ | ភ្នំ | ១៧៨.៩៤២ | ១៥.៦៦៧ | ១៦៣.២៧៥ | ៥៥.១៤៦ | |
| ស្ទឹងត្រែង | ខ្ពង់រាប | ៣៥.៨៣៣ | ៩.៧៦១ | ២៦.០៧២ | ១៧.៤៣៧ | |
| **សរុប** | | | | | **១.២៨៧.០៣១** | |

ថ្ងៃអង្គារ ៦រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤
ហត្ថលេខា

**បណ្ឌិត ហេង គង់**

**បានឃើញ**
**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល និងជាប្រធានកម្មវិធី CAPFISH-Capture**
ថ្ងៃពុធ ២ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០២៤
ហត្ថលេខា

**ពុំ សុថា**